# តើអ្នកបានរកឃើញ

# សោភ័ណភាពពិតរបស់ឥស្លាមហើយឬនៅ?

បណ្ឌិត ណាជី ពិន អ៊ីព្រហ៊ីម អាល់អើរហ្វ៊ិច

និពន្ធដោយ  បណ្ឌិត ណាជី ពិន អ៊ីព្រាហ៊ីម អាល់អើរហ្វ៊ិច

د.ناجى إبراهيم العرفج

អង្គការវប្បធម៌ អារ្យធម៌កម្ពុជា -អារ៉ាប់
Cambodia Arab Cultural Civilizational Organization

# ជំពូកទី១

# មូលដ្ឋានគ្រឹះនៃឥស្លាម

សៀវភៅនេះនឹងអធិប្បាយពីឧទាហរណ៍មួយចំនួនអំពីសោភ័ណភាពពិត និង ឧត្តមភាពនៃឥស្លាម។

- ជំរុញឱ្យប្រកាន់នូវជំហរវិជ្ជមាន បំណងល្អ គំនិតសុទិដ្ឋិនិយម និងអារម្មណ៍ល្អចំពោះអ្នកដទៃ។
- បង្រៀនឱ្យចេះអត់ឱនចំពោះអ្នកដទៃ ស្រលាញ់អ្នកដទៃដូចស្រលាញ់ខ្លួនឯង។
- ជំរុញឱ្យញញឹមរាក់ទាក់ ទឹកមុខស្រស់ស្រាយ មានមនោសញ្ចេតនាល្អចំពោះអ្នកដទៃដោយចេញពីទឹកចិត្តស្មោះត្រង់ និងជ្រះថ្លា។
- ណែនាំឱ្យយើងចេះសំដែងនូវអាកប្បកិរិយាសុភាពរាបសាចំពោះអ្នកដទៃ។
- ណែនាំឱ្យប្រកាន់នូវសីលធម៌ល្អ ទន់ភ្លន់ឱនលំទោនចំពោះមនុស្សទូទៅ។

- បង្រៀនឱ្យចេះប្រាស្រ័យទាក់ទងគ្នាដោយមនោសញ្ចេតនា មេត្តាករុណាចំពោះមនុស្សទូទៅ និងសត្វទាំងឡាយ។
- ប្រៀនប្រដៅឱ្យចេះគោរពឪពុកម្តាយ ចាស់ទុំ និងជួយបីបាច់ថែរក្សាពួកគាត់។ ណែនាំឱ្យចេះធ្វើល្អចំពោះគ្រួសារ ប្រពន្ធកូន សំដែងនូវមនោសញ្ចេតនាអាណិតមេត្តា ផ្តល់ភាពកក់ក្តៅ និងសេចក្តីស្រលាញ់ដល់ពួកគេ។
- ជំរុញឱ្យយើងមានការអនាម័យ ស្អាតស្អំ ទាំងចិត្ត និងកាយ បរិស្ថានជុំវិញ ហើយជំរុញឱ្យចេះសម្អាតផ្លូវដើរពីបន្លាក្រួស និងផលប៉ះពាល់ផ្សេងៗ។
- លើកទឹកចិត្តចំពោះការផ្តល់ជំនួយ ឧបត្ថម្ភចំណីអាហារដល់អ្នកទន់ខ្សោយ ទីទ័លក្រ ខ្វះខាត និងជនពិការ។
- ណែនាំឱ្យចេះត្រិះរិះពិចារណា សញ្ជឹងគិត ចេះប្រើប្រាជ្ញា ចេះបង្កើតច្បាប់ដោយផ្អែកលើមូលដ្ឋានភស្តុតាង និងអំណះអំណាងត្រឹមត្រូវ។

**តើអ្នករកឃើញហើយឬនៅថា សោភ័ណភាពជាអ្វី?**

**មុននឹងបកស្រាយពីអាថ៌កំបាំង ហើយមុននឹងអ្នករកឃើញការពិត ខ្ញុំសូមបង្ហាញប្រាប់ដែរថា...**

- ប្រាប់យើងឱ្យដឹងថា មនុស្សទូទៅមានសិទ្ធិស្មើគ្នា ដោយមិនគិតពីជនជាតិ ពណ៌សម្បុរ និងសញ្ជាតិ។
- បង្គាប់មិនឱ្យយើងធ្វើទុក្ខទោសរំលោភបំពានលើអ្នកដទៃ មិនត្រូវប្រមាថមើលងាយចំពោះកិត្តិយសរបស់ពួកគេ។
- បញ្ជាក់ប្រាប់យើងយ៉ាងច្បាស់ថា នរណាជាអ្នកបង្កើតយើង តើយើងនឹងទៅទីណា តើទីអាស្រ័យចុងក្រោងរបស់យើងជាអ្វី។
- ប្រៀនប្រដៅឱ្យយើងចេះរស់នៅក្នុងសន្តិភាព មានទំនាក់ទំនងល្អជាមួយនឹងអល់ឡោះ (ជាអ្នកបង្កើត) ជាមួយនឹងខ្លួនឯងព្រមទាំងអ្នកដទៃ។
- ឆ្លើយតបបានយ៉ាងជាក់ច្បាស់អំពីសំណួរសំខាន់ៗ និងសំណួរស្លាប់រស់របស់យើង។

តាមពិត វានាំផ្លូវយើងឆ្ពោះទៅកាន់សច្ចភាពដាច់ខាត ទៅកាន់ភាពជោគជ័យ ភាពស្កប់ស្កល់ និងសុភមង្គលពិត សង្គ្រោះចេញពីនរក ទទួលបានជីវិតអមតៈ និងជ័យជំនះដ៏ឧត្តុង្គឧត្តមនៅថ្ងៃបរលោក។

**តើអ្នកជឿទេថា របកគំហើញ**
**នៃការពិតដ៏អស្ចារ្យនេះគឺ...**

# ...ឥស្លាម ?

*នៅពេលដែលប្រាជ្ញារបស់យើងក្លាយជាទាសករនៃភាព លម្អៀង ឬបុរេនិច្ឆ័យ នៅពេលនោះយើងលែងមើលឃើញ សោភ័ណភាព និងធាតុពិតនៃអ្វីមួយជាមិនខាន!*

ជួនកាលអ្នកមានគំនិតអវិជ្ជមានចំពោះឥស្លាម។ ជួនកាល អ្នកមើលឥស្លាមក្នុងរូបភាពមួយដូចជាសារព័ត៌មានបានចុះផ្សាយ ដោយការបំពាក់មុខភេរវកម្មឱ្យឥស្លាម។ ពួកអ្នកប្រព្រឹត្តអំពើនេះជា ជនមួយក្តាប់តូច ដែលប្រកាន់ជ្រុលនិយម និងធ្វើអំពើភេរវកម្មដោយ ពុំគិតពីសាសនា ជនជាតិ (ជាតិសាសន៍) ឬសញ្ជាតិនោះឡើយ។ ជួនកាលអ្នកបានអាន ឬបានឮអំពីឥស្លាមពីប្រភពដែលមិនគួរឱ្យទុក ចិត្ត ខ្វះសុក្រឹតភាព ឬប្រភពដែលប្រកាន់លម្អៀង ដែលព្យាយាម និយាយបង្ខូចឥស្លាម បង្ខូចពួកអ្នកមូស្លីមដោយហេតុផល និងគោល បំណងផ្សេងៗ។

ដូច្នេះ ទើបខ្ញុំអំពាវនាវឱ្យបងប្អូនអានសៀវភៅមួយច្បាប់ នេះជាវត្ថុវិស័យ គំនិតបើកទូលាយ អារម្មណ៍សប្បាយរីករាយជាមួយ

នឹងន័យសេចក្តី និងខ្លឹមសារដែលនិយាយអំពីសោភ័ណភាព គុណសម្បត្តិ ភាពច្បាស់លាស់ និងភាពងាយស្រួលនៃសាសនាឥស្លាម។

**ខាងក្រោមនេះជាឧទាហរណ៍នៃភាពច្បាស់លាស់ សោភ័ណភាព និងលក្ខណៈរបស់សាសនាឥស្លាម៖**

- ភាពច្បាស់លាស់ជុំវិញការបង្កើតភព។
- ភាពច្បាស់លាស់ជុំវិញការបង្កើតមនុស្ស។
- ភាពច្បាស់លាស់ជុំវិញបញ្ហាផ្លូវវិញ្ញាណរបស់យើង (ផ្លូវវិញ្ញាណដែលមានជំនឿត្រឹមត្រូវ)។
- ភាពច្បាស់លាស់និងភាពបរិសុទ្ធក្នុងការយល់អំពីព្រះជាម្ចាស់។
- ភាពច្បាស់លាស់ក្នុងការយល់អំពីការគោរពសក្ការៈ។
- ភាពច្បាស់លាស់ក្នុងផ្លូវទៅរកសុភមង្គលពិត និងភាពរីករាយ។
- ភាពច្បាស់លាស់ជុំវិញថ្ងៃបរលោក។
- ភាពច្បាស់លាស់ជុំវិញទីអាស្រ័យចុងក្រោយរបស់យើង (ឋានសួគ៌ និងឋាននរក)។



មុននឹងយើងចេញដំណើរទៅរកសោភ័ណភាពនិងឧត្ដមភាពនៃឥស្លាម សូមរំឭកឡើងវិញបន្តិចពីបញ្ញត្តិសំខាន់ៗក្នុងឥស្លាមៈ

## អល់ឡោះ (ជាម្ចាស់)

ក្នុងភាសាអារ៉ាប់ *អល់ឡោះ* ជាឈ្មោះរបស់ព្រះតែមួយគត់ ទ្រង់ជាព្រះពិត ហើយទ្រង់ជាអ្នកបង្កើត។ ឥស្លាមបានបង្រៀនយើងថា អល់ឡោះទ្រង់ជាព្រះពិតសម្រាប់មនុស្សលោកទូទៅ។ ពិតប្រាកដណាស់ ពួកជ្វីហ្វ និងពួកគ្រឹស្ទាន ជនជាតិអារ៉ាប់ក៏ប្រើនាមសព្ទនេះ (អល់ឡោះ)ក្នុងន័យព្រះជាម្ចាស់ផងដែរ។



*ឈ្មោះ អល់ឡោះ នៅក្នុង អក្សរវិចិត្រសា ស្ត្រអារ៉ាប់*

## មូហាំម៉ាត់

ជាព្យាការីចុងក្រោយ អល់ឡោះជាម្ចាស់ទ្រង់បានបញ្ជូនមកកាន់មនុស្សលោកទូទៅ។



*ឈ្មោះ មូហាំម៉ាត់ នៅក្នុង អក្សរវិចិត្រសា ស្ត្រអារ៉ាប់*

## ឥស្លាម

ជាការប្រគល់ខ្លួន និងការគោរពប្រណិប័តន៍ ប្រគល់ខ្លួនជូនអល់ឡោះជាម្ចាស់តែមួយអង្គគត់ ព្រោះទ្រង់ជាព្រះពិត។

## មូស្លីម

ជាអ្នកដែលមានជំនឿចំពោះអល់ឡោះ ប្រគល់ខ្លួនជូនទ្រង់ ប្រណិប័តន៍ចំពោះទ្រង់ និងប្រតិបត្តិតាមព្យាការីមូហាំម៉ាត់។

## គម្ពីរអាល់គួរអាន

ជាពាក្យបន្ទូលរបស់អល់ឡោះដែលបានត្រាស់បង្គាប់មកចំពោះព្យាការីមូហាំម៉ាត់ ហើយជាគម្ពីរចុងក្រោយបង្អស់ដែលទ្រង់បានប្រទានចុះមក។



# ជំពូកទី២

# ឆ្លើយតបនឹងសំណួរស្លាប់រស់

ពិតប្រាជកណាស់ ឥស្លាមឆ្លើយតបនឹងសំណួរស្លាប់រស់ និងចម្លល់សំខាន់ៗមួយចំនួនដូចជា៖

- តើអ្វីជាការពិត ?
- តើនរណាជាអ្នកបង្កើតយើង ?
- តើនរណាជាព្រះពិតរបស់យើង ?
- តើនរណាជាព្យាការីចុងក្រោយបង្អស់របស់អល់ឡោះ ?
- តើយើងគោរពសក្ការៈនរណា ?
- តើយើងជានរណា ?
- ហេតុអ្វីបានជាយើងមានវត្តមាននៅក្នុងលោកនេះ ?
- តើក្រោយពេលស្លាប់មានអ្វី ?
- តើអ្វីជាជីវិតនៅថ្ងៃបរលោក ?
- តើអ្វីជាទីអាស្រ័យរបស់យើង(វាសនាចុងក្រោយ) ឋានសួគ៌ ឬឋាននរក ?

- តើយើងគួរធ្វើយ៉ាងដូចម្តេច ដើម្បីទទួលបាននូវសេចក្តីស្ងប់ពិតប្រាកដ? តើយើងគួរធ្វើដូចម្តេចដើម្បីសម្រេចបាននូវសុភមង្គលពិត?
- តើយើងធ្វើដូចម្តេច ដើម្បីទទួលបានជោគជ័យក្នុងជីវិតជាអមតៈ?

*ប្រាជ្ញានិងចិត្ត ជាធាតុសំខាន់ពីរសម្រាប់ស្វែងរកការពិតព្រមជាមួយនឹងការអានដោយស្មោះត្រង់និងទទួលខុសត្រូវហើយធ្វើការវិនិច្ឆ័យដោយខ្លួនឯង។*

## តើអ្វីជាការពិត?

ឥស្លាមបានទទួលស្គាល់ថា អល់ឡោះជាព្រះពិតមានតែមួយអង្គគត់ ទ្រង់បានបង្កើតលោកទាំងមូល។ ទ្រង់ជាព្រះដ៏ឧត្តុង្គឧត្តម ទ្រង់បានបង្កើតមនុស្សលោក និងសត្វទាំងឡាយ ទ្រង់បង្កើតផែនដី ភ្នំ មហាសមុទ្រ រុក្ខជាតិ និងព្រៃព្រឹក្សាទាំងឡាយនៅលើភពផែនដី។ ទ្រង់បង្កើតព្រះអាទិត្យ ព្រះចន្ទ ផ្កាយ គន្លងភព យប់ និងថ្ងៃ។ សត្វលោកទាំងអស់ដែលយើងស្គាល់ក្តី និងមិនស្គាល់ក្តី ឬមិនទាន់រក

ឃើញក្តី ទាំងអស់នោះគ្រាន់តែជាឧទាហរណ៍ខ្លះនៃសត្វលោកដ៏ធំមហាសាលរបស់ទ្រង់ដែលមិនអាចគណនា និងពិពណ៌នាបាន។







អល់ឡោះជាម្ចាស់ទ្រង់ជាអ្នកបង្កើតជីវិត និងសេចក្តីស្លាប់ ទ្រង់បង្កើតជីវិតក្រោយពេលស្លាប់ (ជីវិតបរលោក) ពោលគឺទ្រង់ជាអ្នកបង្កើតអ្វីៗគ្រប់យ៉ាង។

ផ្ទុយទៅវិញ មានអ្នកខ្លះបង្វែរកំណើត និងការរស់រានមានជីវិតរបស់ខ្លួនទៅរកធម្មជាតិ ឬជាជម្រើសធម្មជាតិ។ សុំនិយាយបន្តិចដើម្បីកំណត់ន័យពីអ្វីដែលយើងកំពុងនិយាយអំពីធម្មជាតិ តើធម្មជាតិជាអ្វី? តើធម្មជាតិមានអត្ថន័យយ៉ាងដូចម្តេច?

ខ្ញុំគិតថា យើងទាំងអស់ឯកភាពជាមួយនឹងខ្ញុំថាធម្មជាតិរួមមានភព ផ្កាយ គន្លងភព កាឡាក់ស៊ី (កញ្ចុំផ្កាយ) រុក្ខជាតិ ភ្នំ ជ្រលង ដងអូរ មហាសមុទ្រ ទន្លេ ផែនដី ព្រះអាទិត្យ ព្រះចន្ទ្រ និងផ្កាយ។ល។

តើអ្វីទាំងអស់នេះកើតមកដោយឯកឯង ឬក៏អ្វីទាំងនោះជាអ្នកបង្កើតមនុស្សលោក?



គម្ពីរអាល់គួរអានបានបង្ហាញយើងយ៉ាងច្បាស់លាស់ និងប្រកបដោយសោភ័ណភាពថា៖

يَٰٓأَيُّهَا ٱلنَّاسُ ٱعۡبُدُواْ رَبَّكُمُ ٱلَّذِي خَلَقَكُمۡ وَٱلَّذِينَ مِن قَبۡلِكُمۡ لَعَلَّكُمۡ تَتَّقُونَ
البقرة: ٢١

មានន័យថា៖ «ម្នាលមនុស្សលោកទាំងឡាយ ចូរគោរពសក្ការៈចំពោះព្រះជាម្ចាស់របស់ពួកអ្នកចុះ ព្រោះទ្រង់ដែលបានបង្កើតពួកអ្នក និងបង្កើតមនុស្សជំនាន់មុនពួកអ្នក ដោយសង្ឃឹមថា អ្នកទាំងអស់គ្នាកោតខ្លាចចំពោះទ្រង់»។

خَلَقَ ٱلسَّمَٰوَٰتِ وَٱلۡأَرۡضَ بِٱلۡحَقِّۖ يُكَوِّرُ ٱلَّيۡلَ عَلَى ٱلنَّهَارِ وَيُكَوِّرُ ٱلنَّهَارَ عَلَى ٱلَّيۡلِۖ وَسَخَّرَ ٱلشَّمۡسَ وَٱلۡقَمَرَۖ كُلّٞ يَجۡرِي لِأَجَلٖ مُّسَمًّىۗ أَلَا هُوَ ٱلۡعَزِيزُ ٱلۡغَفَّٰرُ
الزمر: ٥

មានន័យថា៖ «ទ្រង់បានបង្កើតមេឃច្រើនជាន់ និងផែនដីប្រកបដោយសច្ចភាព ទ្រង់បង្កើតយប់បន្ទាប់ពីថ្ងៃ ហើយបង្កើតថ្ងៃបន្ទាប់ពីយប់ ទ្រង់ដាក់ព្រះអាទិត្យនិងព្រះចន្ទនៅក្រោមប្រព័ន្ធមួយយ៉ាងសុក្រឹត ទាំងអស់នោះធ្វើចលនាតាមគន្លងរបស់វារហូតដល់ថ្ងៃ

បរលោក។ តើមិនមែនទេឬដែលថា ទ្រង់មហាខ្លាំងពូកែ និងមហាអភ័យ»។

وَهُوَ ٱلَّذِى خَلَقَ ٱلَّيْلَ وَٱلنَّهَارَ وَٱلشَّمْسَ وَٱلْقَمَرَ كُلٌّ فِى فَلَكٍ يَسْبَحُونَ الأنبياء: ٣٣

មានន័យថា៖ «អ្វីដែលទ្រង់បានបង្កើតមានយប់ ថ្ងៃ ព្រះអាទិត្យ និងព្រះចន្ទ្រ ទាំងអស់សុទ្ធតែកំពុងធ្វើចលនាក្នុងគន្លងទាំងអស់»។

ម្យ៉ាងវិញទៀតពួកអ្នកជឿលើធម្មជាតិបានប្រកែកថាខ្លួនមិនជឿចំពោះអល់ឡោះនោះទេ ព្រោះតាមធម្មតាពួកគេយកលេសថា ពួកគេមិនឃើញទ្រង់ ឬមិនអាចប៉ះទ្រង់ ឬមិនអាចធ្វើការសាកល្បងជាមួយនឹងអល់ឡោះជាម្ចាស់មហាពិសិដ្ឋបានទេ។

កាលពីប៉ុន្មានឆ្នាំមុន ពេលដែលខ្ញុំទៅលេងផ្ទះរបស់ខ្ញុំនៅរដ្ឋអូរេហ្គិននៃសហរដ្ឋអាមេរិក ខ្ញុំបាននិយាយជាមួយអ្នកជិតខាងពីរឿងផ្សេងៗ ក្នុងនោះក៏មាននិយាយអំពីការស្វែងយល់អំពីព្រះជាម្ចាស់ និងការមានវត្តមានរបស់ទ្រង់។

អ្នកជិតខាងខ្ញុំចំណាស់ម្នាក់នេះបានប្រកែកថា មិនមានអល់ឡោះទេ ដោយគាត់យកដៃទះតុយ៉ាងស្វាហាប់ ហើយនិយាយថា ខ្ញុំជឿថា នេះគឺជាតុ ព្រោះខ្ញុំអាចប៉ះវាបាន ខ្ញុំអាចដឹងដោយឥន្ទ្រីយារម្មណ៍របស់ខ្ញុំ។

ខ្លួនខ្ញុំព្យាយាមសន្ទនាជាមួយគាត់ដោយលើកហេតុផលតាមរយៈការប្រើគំនិតគិត ខ្ញុំបានចង្អុលទៅអំពូលភ្លើងក្នុងបន្ទប់ រួចសួរគាត់ថា តើអ្នកជឿថា មានថាមពល ឬកម្លាំងចរន្តអគ្គិសនីដែរឬទេ?

គាត់ឆ្លើយថា ពិតហើយ។

ខ្ញុំសួរគាត់ទៀតថា តើលោកអាចមើលឃើញកម្លាំងចរន្តអគ្គិសនីឬថាមពលដែលបង្កើតឱ្យមានពន្លឺនោះទេ?

គាត់ឆ្លើយថា ទេ។

បន្ទាប់មក ខ្ញុំក៏បានសួរប៉ុន្មានសំណួរទៀតថា៖

- តើលោកមើលឃើញខ្យល់ដែលយើងដកដង្ហើមចេញចូលដោយផ្ទាល់ភ្នែកទេ?
- តើលោកមានអារម្មណ៍ទេ? តើអារម្មណ៍របស់លោកមានពណ៌សម្បុរ រូបរាង និងទំហំ យ៉ាងដូចម្ដេចដែរ?
- តើការដេកជាអ្វី? មានពណ៌ និងទម្ងន់យ៉ាងដូចម្ដេច?

- តើមានអ្វីខ្លះដែលយើងជឿថា មានពិត តែយើងមើលវាមិនឃើញ?

ម្យ៉ាងវិញទៀត នៅថ្ងៃមួយខ្ញុំបានជួបជាមួយយុវជនម្នាក់ឈ្មោះ គ្រិស្ត និងប្រពន្ធរបស់គាត់នៅសណ្ឋាគារមួយក្នុងទីក្រុង អូស្លូ ប្រទេសន័រវែស។ ខ្ញុំបានជជែកគ្នាលេងជាមួយនឹងគេ ហើយខ្ញុំបានសួរគេថា គ្រិស្ត! តើអ្វីជាគោលបំណងនៃជីវិត? គ្រិស្តបានតបមកខ្ញុំដោយភ្ញាក់ផ្អើលថា នេះជាសំណួរដំបូងបង្អស់ដែលខ្ញុំឮ គេបានបន្ថែមទៀតថា ខ្ញុំគិតថា ជីវិតរបស់ខ្ញុំអត់មានគោលបំណងអ្វីទេ គេបញ្ចប់សម្តីរបស់គេដោយនិយាយថា ខ្ញុំមិនជឿលើព្រះណាមួយនោះឡើយ។ ខ្ញុំសួរគេថា ហេតុអ្វី?

គេឆ្លើយថា ព្រោះខ្ញុំមិនដែលឃើញ។ ភ្ជាប់នឹងចម្លើយរបស់គេ ខ្ញុំបានសួរគេទាំងញញឹមថា៖

- តើអ្នកស្រលាញ់ប្រពន្ធរបស់អ្នកទេ?
- តើអ្នកអាចឃើញសេចក្តីស្រលាញ់នេះដោយចក្ខុវិញ្ញាណរបស់អ្នកទេ?
- តើសេចក្តីស្រលាញ់របស់អ្នកមានពណ៌អ្វី?
- តើសេចក្តីស្រលាញ់នេះមានទម្ងន់ប៉ុណ្ណា?

តើគ្រិស្ត និងប្រពន្ធរបស់គាត់មានប្រតិកម្មយ៉ាងដូចម្ដេច? ចូរព្យាយាមគិត និងត្រិះរិះពិចារណា!

ដូច្នេះ ដោយគ្រាន់តែសមត្ថភាពរបស់យើងមើលមិនឃើញ ឬ វាស់វែងមិនបានដូចជា សេចក្ដីស្រលាញ់ និងអារម្មណ៍ ដោយការប៉ះ ឬកាន់តែប៉ុណ្ណោះ ពុំមែនមានន័យថា យើងត្រូវតែបដិសេធរាល់ធាតុពិត និងវត្ថុមាននៃសេចក្ដីស្រលាញ់ ឬអារម្មណ៍របស់យើងនោះទ្បើយ។

ក៏ដូចគ្នានេះដែរ បើសិនជា យើងមិនអាចមើលឃើញអល់ឡោះក្នុងជីវិតនេះដោយហេតុថា វិញ្ញាណរបស់យើងមានដែនកំណត់ ហើយសមត្ថភាពរបស់យើងមិនអាចដឹងពីវិសាលភាពរបស់ទ្រង់បានទេ។ ដូច្នេះ យើងមិនត្រូវបដិសេធចំពោះវត្តមានភាពរបស់អល់ឡោះនោះឡើយ។

ពិតប្រាកដ វត្តមានរបស់អល់ឡោះជាម្ចាស់មានភាពច្បាស់លាស់ណាស់ ដោយយើងអាចតាមដានដឹងពីហេតុផលរបស់វាដោយងាយស្រួលតាមរយៈនិមិត្តសញ្ញា អំណះអំណាង និងភស្ដុតាងដែលគ្មានដែនកំណត់។ ភស្ដុតាងនិងអំណះអំណាងទាំងនោះលាតត្រដាងឡើងក្នុងការបង្កើតបរិមាណដែលមិនអាចគណនាបាន ដូចជាធាតុ

អាតូម កោសិកា ផាលិកា សសៃប្រសាទ និងអ្វីគ្រប់យ៉ាងដែលជាសភាវសត្វលោក។

លើសពីនេះ មានអ្នកនាំសាររបស់ព្រះរាប់ពាន់នាក់ និងពួកអ្នកដើរតាមរាប់ពាន់លាននាក់ក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ពួកគេបញ្ជាក់ថា មានអល់ឡោះ ហើយបាននាំគ្នាជឿចំពោះទ្រង់។ តើសមហេតុផលនិងមានតក្កភាពដែរឬទេចំពោះអ្នកធ្វើមិនដឹងមិនឮ មិនយកបញ្ហាមកគិតអំពីសាក្សីនៃមនុស្សរាប់ពាន់លាននាក់ដែលជាជ្រុងមួយនៃនិមិត្តសញ្ញា? តើដោយហេតុតែទស្សនៈខ្លះ ទើបធ្វើឱ្យមនុស្សបដិសេធនឹងភស្តុតាងឬ? (ដូចជាទស្សនៈនៃការវិវឌ្ឍរបស់សាល ដារវីន ដែលបានបដិសេធនឹងភស្តុតាងទាំងឡាយដោយសារតែការសិក្សាស្រាវជ្រាវ និងបទពិសោធរបស់ខ្លួន)។

នេះជាការពិតដ៏បរិសុទ្ធក្នុងសាសនាឥស្លាម ដែលបញ្ជាក់ពីវត្តមានរបស់អល់ឡោះនិងជឿចំពោះទ្រង់តែមួយគត់ គ្មានព្រះជាម្ចាស់លើកលែងតែអល់ឡោះ ទ្រង់ជាអ្នកបង្កើតលោកទាំងមូល ហើយទ្រង់ជាព្រះដ៏មហាពិសិដ្ឋ។

យើងចាំបាច់ត្រូវតែជឿថា គ្មាននរណាម្នាក់ ហើយគ្មានអ្វីមួយខ្ពស់ជាងទ្រង់ ឬដូចទ្រង់ឡើយ។ ប្រាកដណាស់ អល់ឡោះជាព្រះពិត

ទ្រង់បានបង្កើតពួកយើង ដើម្បីឱ្យយើងស្គាល់ទ្រង់ និងគោរពសក្ការៈចំពោះទ្រង់តែមួយគត់។ ពួកអ្នកដែលគោរពសក្ការៈចំពោះទ្រង់បានត្រឹមត្រូវ ប្រតិបត្តិតាមការបង្គាប់របស់ទ្រង់ដោយពេញលេញនោះ នឹងបានចូលឋានសួគ៌ (ជីវិតអមតៈ)។ ផ្ទុយទៅវិញ ពួកអ្នកដែលប្រព្រឹត្តល្មើសនឹងទ្រង់ ធ្វើតាមទំនើងចិត្ត និងកិលេសតណ្ហានោះនឹងទៅកាន់....

តើអ្នកគិតថា នឹងទៅទីណា?

ក្នុងចំណោមពួកយើងនរណាក៏អាចទទួលបាននូវសុភមង្គលពិត និងសេចក្តីស្ងប់ពិតប្រាកដដោយគ្រាន់តែជឿ និងប្រគល់ខ្លួនប្រតិបត្តិចំពោះអល់ឡោះជាម្ចាស់ជាការស្រេច។

## តើនរណាជាព្រះពិត?

គម្ពីរអាល់គួរអានបានឆ្លើយនឹងសំណួរដ៏សំខាន់នេះយ៉ាងច្បាស់លាស់ថា៖




មានន័យថា៖ «ក្នុងព្រះនាមអល់ឡោះ ទ្រង់មហាមេត្តា មហាករុណា»។

«មូហាំម៉ាត់! ចូរប្រកាសចុះថា អល់ឡោះគឺជាម្ចាស់តែមួយគត់។ ទ្រង់គង់ជាអមតៈ ទ្រង់គ្មានកូន និងគ្មាននរណាបង្កើតទ្រង់ ហើយគ្មាននរណាម្នាក់ដូចទ្រង់ឡើយ»។

នេះគឺជាជំពូកពេញលេញមួយនៃគម្ពីរអាល់គួរអាន ជាជំពូកប្រសើរបំផុតដែលប្រាប់យើងដោយសង្ខេប និងច្បាស់លាស់ដោយនិយាយតែការពិតអំពីអល់ឡោះជាម្ចាស់តែមួយគត់ និងលក្ខណៈសម្បត្តិពិតរបស់ទ្រង់។ ជំពូកនេះបានឆ្លើយតបយ៉ាងច្បាស់លាស់នឹងសំណួរស្លាប់រស់ និងសំខាន់បំផុត ដែលមានមនុស្សរាប់ពាន់លាននាក់កំពុងមានចម្ងល់វិលវល់ច្របល់នៅក្នុងចិត្ត។

តាមរយៈជំពូកដ៏ប្រសើរនេះ និងមាត្រាផ្សេងៗក្នុងគម្ពីរ នាំឱ្យយើងអាចស្គាល់ពីលក្ខណសម្បត្តិខ្លះដែលញែកឱ្យដាច់រវាងព្រះពិត និងព្រះដទៃដែលមិនពិត។ លក្ខណៈសម្បត្តិពិសេសរបស់ទ្រង់គឺៈ

- ព្រះពិតគឺទ្រង់ជាអ្នកបង្កើត ពុំមែនត្រូវគេបង្កើតទ្រង់នោះឡើយ។
- ព្រះពិតគឺទ្រង់មានតែមួយ ទ្រង់គ្មានដៃគូ ទ្រង់ពុំមានចំនួនច្រើនអង្គ ទ្រង់គ្មានមាតាបិតា ហើយទ្រង់គ្មានបុត្រ។
- អល់ឡោះទ្រង់ប្រកបដោយភាពស្អាតស្អំពីគំនិតយល់ឃើញរបស់មនុស្សលោក ហើយចក្ខុវិញ្ញាណរបស់មនុស្សលោកមិនអាចមើលឃើញទ្រង់ក្នុងលោកីយ៍នេះឡើយ។

- អល់ឡោះទ្រង់មានភាពអមតៈពីបុព្វេ ទ្រង់មិនស្លាប់ ទ្រង់មិនប្រែប្រួល មិនសាបសូន្យ មិនបែងភាគ មិនចូលសណ្ឋិតក្នុងអ្វីមួយនៃសភាវសត្វលោក។
- អល់ឡោះទ្រង់គង់ជាអមតៈដោយព្រះអង្គឯង ដោយមិនត្រូវការពឹងពាក់ពីសត្វលោក ទ្រង់គ្មានមាតាបិតា ទ្រង់គ្មានប្រពន្ធកូន ទ្រង់មិនត្រូវការចំណីអាហារ មិនត្រូវការជំនួយពីនរណាម្នាក់ឡើយ។ ក៏ប៉ុន្តែសត្វលោកទាំងឡាយដែលទ្រង់បានបង្កើតវិញទេដែលត្រូវការទ្រង់នោះ។
- អល់ឡោះជាម្ចាស់តែមួយគត់ ទ្រង់មានលក្ខណសម្បត្តិថ្លៃថ្លាសុក្រឹតពេញលេញ ប្រកបដោយសោភ័ណភាព ហើយគ្មានសត្វលោកណាមួយមានលក្ខណៈទាំងនេះដូចទ្រង់ ពោលគឺគ្មានអ្វីមួយដូចទ្រង់ឡើយ។





## តើអ្នករកអាថ៌កំបាំងឃើញហើយឬនៅ?



តាមពិត ឥស្លាមរក្សានូវធម្មជាតិនៃឧបនិស្ស័យ ដែលអល់ឡោះជាម្ចាស់ទ្រង់បានបង្កើតយើងឱ្យ មានមកជាមួយនឹងជាតិកំណើតរបស់យើង។ ប្រាដកណាស់ អល់ឡោះជាម្ចាស់ទ្រង់ដឹងពី អាថ៌កំបាំង ការគិត ប្រាជ្ញា និងចិត្ត របស់យើង ហើយទ្រង់ប្រាប់យើងឱ្យដឹងពីអាថ៌កំបាំង និងកូនសោនៃសេចក្តីស្ងប់ សេចក្តីសុខសម្រាប់ខ្លួនប្រាណ ប្រាជ្ញា ស្មារតី និងចិត្តគំនិតរបស់យើង។

## តើធ្វើដូចម្តេចដើម្បីធ្វើឱ្យយើងមានអារម្មណ៍ស្រស់ស្រាយ និងមានសេចក្តីស្ងប់?

1. ចូរស្គាល់ព្រះជាម្ចាស់តែមួយរបស់អ្នក។
2. ចូរមានជំនឿចំពោះទ្រង់ (កុំបង្កើតដៃគូសម្រាប់ទ្រង់)។
3. ប្រតិបត្តិតាមការបង្គាប់បញ្ជារបស់ទ្រង់។
4. ចូរជឿចំពោះពួកអ្នកនាំសាររបស់ទ្រង់ (និងអ្នកនាំសារមូហាំម៉ាត់)។
5. ចូរសូត្រធម៌រំឭកចំពោះទ្រង់។
6. ចូរបួងសួងសុំការអភ័យទោសពីទ្រង់។
7. ចូរគោរពសក្ការៈចំពោះអល់ឡោះតែមួយគត់។
8. ចូរស្រលាញ់អ្នកដទៃដូចជាអ្នកស្រលាញ់ខ្លួនឯង។
9. បើកចិត្តឱ្យទូលាយនិងព្យាយាមធ្វើឱ្យអ្នកដទៃបានសុខ។
10. ចូរជ្រះថ្លា និងកោតខ្លាចចំពោះទ្រង់។

សង្ខេបរួមមក កូនសោទាំងដប់នេះយើងអាចសម្រេចបាននូវសេចក្តីស្ងប់ សេចក្តីសុខសុភមង្គលផ្លូវចិត្ត សង្គម និងពិភពលោកទាំងមូល ហើយខ្លឹមសារទាំងនេះស្រង់ចេញពីកំណាប់ នៃគម្ពីរអាល់គួរអាន និងប្រសាសន៍របស់អ្នកនាំសារមូហាំម៉ាត់។

ដើម្បីសង្ខេបនូវគំនិតនេះ ឥស្លាមបានចង្អុលបង្ហាញយើងតាមរយៈប្រភពពីរសំខាន់ គឺគម្ពីរអាល់គួរអាន និងធម្មនិយមរបស់អ្នកនាំសារ អាចធ្វើឱ្យយើងសម្រេចបាននូវសន្តិភាព សុភមង្គល និងការសង្គ្រោះដោយការស្គាល់អល់ឡោះជាព្រះពិតតែមួយគត់ មានជំនឿពេញលក្ខណៈ និងមានភាពស្មោះត្រង់ចំពោះទ្រង់។ ជាមួយគ្នានេះយើងចាំបាច់ត្រូវមានជំនឿចំពោះពួកអ្នកនាំសារទាំងឡាយ (**ក្នុងចំណោមពួកគេ គឺអ្នកនាំសារមូហាំម៉ាត់**) ប្រតិបត្តិតាមសេចក្ដីចង្អុលបង្ហាញ និងការទូន្មានប្រៀនប្រដៅរបស់ពួកគាត់។

**ផ្លូវដែលនាំយើងឆ្ពោះទៅកាន់ជីវិតដ៏មានសុភមង្គល សេចក្ដីស្ងប់ និងជីវិតអមតៈ** នោះគឺតាមរយៈជំនឿចំពោះពាក្យសច្ចាទាំងពីរដែលពោលថា៖

أشهد أن لا إله إلا الله وأشهد أن محمدا رسول الله

*ខ្ញុំសូមសច្ចាថា គ្មានព្រះណាក្រៅពីអល់ឡោះឡើយ ហើ សូមសច្ចាថា មូហាំម៉ាត់ជាអ្នកនាំសាររបស់អល់ឡោះ។*

ម្យ៉ាងវិញទៀត ឥស្លាមបានប្រាប់យើងថា ជំនឿចំពោះអល់ឡោះ និងពួកអ្នកនាំសាររបស់ទ្រង់តែមួយមុខនោះ ពុំទាន់គ្រប់គ្រាន់ដើម្បីសម្រេចនូវសេចក្តីស្ងប់និងការសង្គ្រោះនោះនៅឡើយទេ។

យើងចាំបាច់ត្រូវប្រតិបត្តិនូវអំពើល្អ គោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់តែមួយគត់ ប្រតិបត្តិតាមការបង្គាប់របស់ទ្រង់ និងជៀសវាងពីអ្វីដែលទ្រង់ហាមប្រាម។

ប្រាកដណាស់ ការគោរពប្រណិប័តន៍តាមការបង្គាប់របស់អល់ឡោះគឺជាធាតុស្នូលនៃសាររបស់ទ្រង់។ ពាក្យថា ការគោរពប្រណិប័តន៍ និងការស្តាប់បង្គាប់ចំពោះអល់ឡោះ ក្នុងភាសាអារ៉ាប់គឺមានប្រភពមកពីពាក្យឥស្លាម។

ជាការពិតណាស់ អត្ថន័យនៃការគោរពប្រណិប័តន៍ចំពោះអល់ឡោះ និងអ្វីដែលទ្រង់បានត្រៀមប្រទាផលបុណ្យដល់ពួកអ្នកដែលមានជំនឿ និងប្រតិបត្តិអំពើល្អ។ ទ្រង់បានមានព្រះបន្ទូលក្នុងគម្ពីរអាល់គួរអានថា៖

إِنَّ ٱلَّذِينَ ءَامَنُواْ وَعَمِلُواْ ٱلصَّٰلِحَٰتِ كَانَتْ لَهُمْ جَنَّٰتُ ٱلْفِرْدَوْسِ نُزُلًا الكهف: ١٠٧

មានន័យថា៖ «ពិតណាស់ ពួកអ្នកមានជំនឿ និងបានប្រតិបត្តិអំពើល្អ សម្រាប់ពួកគេគឺឋានសួគ៌ផារ៉ាដៃជាទីស្នាក់អាស្រ័យ»។

ក្នុងន័យធៀបគម្ពីរពិសិដ្ឋបានចែងដូចតទៅ៖

**«ពិតណាស់ រូបកាយដែលគ្មានព្រលឹងប្រៀបដូចជាសាកសព ហើយជំនឿគ្មានការប្រតិបត្តិក៏ប្រៀបដូចជាសាកសពផងដែរ» (ស្តេចជេម ២:២៦)។**

ក្នុងជំពូកដដែលនេះបានបង្ហាញអត្ថន័យនៃឥស្លាមដែលយើងបានជជែកពីខាងដើម។

**«ចូរគោរពប្រណិប័តន៍ចំពោះអល់ឡោះចុះ»(ស្តេចជេម៤:៧)។**

ដូច្នេះ អ្នកមូស្លីម ជាអ្នកដើរតាមយេស៊ូ និងពួកអ្នកនាំសារទាំងឡាយដ៏ស្មោះត្រង់។ ពិតប្រាកដ អ្នកមូស្លីមជាបុគ្គលដែលគោរពប្រណិប័តន៍ និងឱនលំទោនចំពោះក្តីបង្គាប់របស់អល់ឡោះជាម្ចាស់។

អ្នកមូស្លីមមានជំនឿចំពោះអល់ឡោះជាព្រះពិតតែមួយគត់។ ពួកគេប្រតិបត្តិអំពើល្អ គោរព និងប្រណិប័តន៍តាមការបង្គាប់ និងពាក្យផ្តែផ្តាំដែលពួកព្យាការី និងពួកអ្នកនាំសារបាននាំមក ដូចជាការមានជំនឿចំពោះអល់ឡោះ ការថ្វាយបង្គំ ការក្រាបបង្គំ ការឱនគោរព ការបង់ហ្សាកាត់ ការធ្វើទាន និងការពោលពាក្យ (إن شاء الله) មានន័យថា «**បើទ្រង់សព្វព្រះទ័យ**» ការផ្សព្វផ្សាយសាឡាមដោយពោលថា (السلام عليكم)មានន័យថា (**សូមសិរីសួស្តីកើតមានចំពោះពួកអ្នកទាំងអស់គ្នា**)។

នេះគឺជាអ្វីដែលពួកព្យាការីបានអនុវត្ត (ក្នុងចំណោមពួកគេមាន មូសា អ៊ីសា មូហាំម៉ាត់)។ នេះគ្រាន់តែជាឧទាហរណ៍គំរូ និងភស្តុតាងខ្លះបញ្ជាក់ពីសច្ចភាពដ៏ត្រចះត្រចង់ បញ្ជាក់ពីសកលនីយកម្មនៃសារតែមួយរបស់សាសនាដ៏ឧត្តមនិងប្រសើរថ្លៃថ្លា សម្រាប់គ្រប់ព្យាការី និងពួកអ្នកនាំសាររបស់ទ្រង់នោះគឺ**សាសនាឥស្លាម**។

ជាការចាំបាច់ចំពោះអ្នកមូស្លីម ឬបុគ្គលដែលចង់ក្លាយជាមូស្លីមត្រូវតែមានជំនឿចំពោះគោលជំនឿទាំងប្រាំមួយ។

## គោលជំនឿទាំងប្រាំមួយគឺ៖

1. **ជឿចំពោះអល់ឡោះ (ជាព្រះពិតតែមួយគត់)៖** ក្នុងគោលជំនឿនេះរួមមានការជឿចំពោះអល់ឡោះ ទទួលស្គាល់ទ្រង់ជាព្រះជាម្ចាស់ និងជាព្រះដែលត្រូវគេគោរពសក្ការៈតែមួយគត់ ទ្រង់មានព្រះនាម និងព្រះលក្ខណៈ ហើយគ្មានព្រះដែលត្រូវគេគោរពសក្ការៈយ៉ាងពិតប្រាកដលើកលែងតែទ្រង់។
2. **ជឿចំពោះពួកទេវតា៖** ព្រះបង្កើតពួកគេមកដើម្បីសូត្រធម៌រំឭកដល់អល់ឡោះជាម្ចាស់តែមួយគត់ ពោលពាក្យសរសើរលើកតម្កើង គោរពប្រណិប័តន៍ និងអនុវត្តតាមបទបញ្ជារបស់ទ្រង់។
3. **ជឿចំពោះព្រះគម្ពីរ** រួមមាន ព្រះបន្ទូលដែលទ្រង់បានត្រាស់បន្ទូលទៅកាន់ មូសា អ៊ីសា (ពុំមែនជាសៀវភៅនិពន្ធ ឬរឿងនិទានដែលគេប្រឌិតឡើងនោះទេ)។ គម្ពីរអាល់គួរអានវិញ ជាការត្រាស់បន្ទូលចុងក្រោយបង្អស់របស់អល់

ទ្បោះទៅកាន់ព្យាការីមូហាំម៉ាត់ ហើយទ្រង់បានរក្សាគម្ពីរនេះមិនឱ្យគេកែប្រែ លុបបំបាត់ និងបន្ថែមបន្ថយឡើយ។

4. **ជឿចំពោះពួកអ្នកនាំសាររបស់ទ្រង់** រួមមាន ណួហ អ៊ីព្រហ៊ីម មូសា អ៊ីសា និងមូហាំម៉ាត់ សូមសន្តិភាពកើតមានចំពោះពួកគាត់។ ដូច្នេះ អ្នកមូស្លីមពុំទាន់មានជំនឿពិតប្រាកដទេ លុះត្រាតែមានជំនឿចំពោះមូសា និងអ៊ីសាជាព្យាការីដែលអល់ទ្បោះជាម្ចាស់បានបញ្ជូនមកកាន់មនុស្សលោក។

5. **ជឿចំពោះថ្ងៃបរលោក** ថ្ងៃរស់ឡើងវិញ និងថ្ងៃជំនុំជម្រះ។ អល់ទ្បោះជាម្ចាស់ទ្រង់នឹងកាត់ក្តីចំពោះមនុស្សលោកនៅថ្ងៃបរលោកតាមជំនឿ និងការប្រតិបត្តិរបស់ពួកគេនាថ្ងៃនោះ។ ក្រោយពីកាត់ក្តី និងជំនុំជម្រះរួច នឹងដឹងថា អ្នកដែលត្រូវចូលឋានសួគ៌ទទួលបាននូវជីវិតដ៏មានបរមសុខអតមៈ និងអ្នកដែលត្រូវគេបោះចូលទៅក្នុងភ្លើងនរក។

6. **ជឿចំពោះព្រះលិខិត**ដែលត្រូវបានកំណត់ដោយពុទ្ធិរបស់ទ្រង់ដ៏ជាក់លាក់។ ពិតប្រាកដ ការជឿចំពោះព្រះលិខិតធ្វើឱ្យអ្នកមូស្លីមមានទំនុកចិត្តជឿជាក់ចំពោះអល់ទ្បោះ។ ពួកគេពេញចិត្ត ស្កប់ស្កល់ចំពោះអ្វីដែលទ្រង់បានកំណត់

ចំពោះពួកគេ ទោះល្អ ឬអាក្រក់។ ពិតណាស់ ពួកអ្នកដែលមានជំនឿចំពោះអល់ឡោះ និងព្រះលិខិតរបស់ទ្រង់ នឹងមិនអស់សង្ឃឹម មិនខកចិត្ត មិនខកបំណង នៅពេលដែលពួកគេប្រទះនឹងវិបត្តិ ឬគ្រោះថ្នាក់។ ពួកគេតម្រង់ឆ្ពោះទៅរកអល់ឡោះ បួងសួងសុំឱ្យទ្រង់ជួយ និងសារភាពចំពោះទ្រង់។

ជំនឿចំពោះអល់ឡោះ និងព្រះលិខិតដ៏ប្រពៃរបស់ទ្រង់នេះធ្វើឱ្យអ្នកមូស្លីមមានអារម្មណ៍ស្កប់ស្កល់ រីករាយស្រស់ស្រាយ ពេញចិត្ត បើទោះជាខ្លួនត្រូវទទួលរងនូវការបៀតបៀន ការជិះជាន់ដោយអំពើអយុត្តិធម៌ ការប្រកាន់ពូជសាសន៍ និងការមួលបង្កាច់បង្ខូចឈ្មោះដែលគេកំពុងប្រឈមមុខក៏ដោយ។

និយាយរួម នេះគឺជាគោលជំនឿក្នុងឥស្លាមដែលតម្រូវឱ្យពួកអ្នកមានជំនឿស្មោះភក្តីចាំបាច់ត្រូវតែគោរពតាម។

# គោលគ្រឹះឥស្លាមទាំងប្រាំ



បន្ថែមពីលើគោលជំនឿទាំងប្រាំមួយខាងលើ សាសនាឥស្លាមបានចង្អុលបង្ហាញថា ជំនឿត្រូវភ្ជាប់ជាមួយនឹងការប្រតិបត្តិ និងអនុវត្តជាក់ស្តែង។ ដូច្នេះអ្នកមូស្លីម ត្រូវតែប្រតិបត្តិនូវគោលគ្រឹះឥស្លាមទាំងប្រាំ និងអំពើល្អទាំងឡាយ។

គោលគ្រឹះឥស្លាមទាំងប្រាំមានអត្ថន័យសង្ខេបដូចខាងក្រោម៖

1. ពាក្យសច្ចាទាំងពីរ៖

   *(ខ្ញុំសូមសច្ចាថា គ្មានព្រះជាម្ចាស់ក្រៅពីអល់ឡោះ និងមូហាំម៉ាត់ជាអ្នកនាំសាររបស់អល់ឡោះ)*។

សូត្រជាភាសាអារ៉ាប់«*អាស្ហាហាហ្ទូអាល់ឡាអ៊ីឡាហា អ៊ីលឡាអល់ឡោះ វ៉ាអាស្ហាហាហ្ទូ អាន់ណា មូហាំម៉ាហ្ទាន់រ៉ស៊ូលុលឡោះ*»។




នេះគឺជាពាក្យសច្ចាដែលតម្រូវឱ្យបុគ្គលដែលចូលឥស្លាមត្រូវពោល។ ពិតណាស់ នេះឆ្លុះបញ្ចាំងពីសោភ័ណភាព និងភាពងាយស្រួលនៃសាសនាឥស្លាម។

## 2. ការថ្វាយបង្គំ



ការថ្វាយបង្គំប្រាំដងជាកាតព្វកិច្ច (រួមមាន ការឈរ ការឱនគោរព ការក្រាបគោរព ការសូត្រផ្នែកខ្លះនៃគម្ពីរអាល់គួរអាន ការសរសើរចំពោះអល់ឡោះ ការសូត្រធម៌រំឭកចំពោះទ្រង់ ការបួងសួងសុំក្ដីមេត្តា ការខន្តីអភ័យ និងបួងសួងសុំឋានសួគ៌អំពីទ្រង់)។

សោភ័ណភាពនៃការថ្វាយបង្គំបង្ហាញឱ្យឃើញថា ការថ្វាយបង្គំជួយបណ្ដុះនូវភាពស្ងប់ស្ងាត់ក្នុងចិត្ត ភាពរីករាយ មានជំនួយ ស្ងប់អារម្មណ៍ និងប្រាជ្ញាស្មារតី។

សោភ័ណភាពនៃការថ្វាយបង្គំគឺធ្វើឱ្យអារម្មណ៍រីករាយដឹងច្បាស់ថា ពួកព្យាការីរបស់អល់ឡោះ និងពួកអ្នកនាំសាររបស់ទ្រង់ ដូចជា អាដាំ ណួហ អ៊ីព្រហ៊ីម មូសា អ៊ីសា និងមូហាំម៉ាត់ ពួកគាត់ក៏ធ្លាប់បានប្រតិបត្តិនូវការថ្វាយបង្គំនេះ និងក្រាបគោរពចំពោះអល់ឡោះជាម្ចាស់ដូចខ្លួនដែរ។ ដូច្នេះ ពួកអ្នកមូស្លីមដើរតាមគន្លងរបស់ពួកព្យាការីរបស់អល់ឡោះ និងពួកអ្នកនាំសាររបស់ទ្រង់។

លើសពីនេះ មេរៀន និងគំនិតអប់រំផ្សេងជាច្រើនទៀតលាតត្រដាងឡើងយ៉ាងច្បាស់លាស់តាមរយៈការថ្វាយបង្គំ ហើយអ្នកមូស្លីមអាចរៀនសូត្រពីការថ្វាយបង្គំនេះដូចជា ការស្រលាញ់អល់ឡោះ ការគោរពប្រតិបត្តិ ការឱនលំទោន ការប្រគល់ខ្លួន ជឿចំពោះទ្រង់តែមួយគត់ ការបួងសួង ចិត្តជ្រះថ្លា ការអត់ធ្មត់ ការបន្ទាបខ្លួន និងសមភាពសង្គមសម្រាប់មនុស្សទូទៅ។

តាមការពិត ការសូត្រធម៌រំឭកចំពោះអល់ឡោះដោយចិត្តជ្រះថ្លា ការឱនលំទោន ការបួងសួង ការសុំអភ័យទោស ការថ្វាយបង្គំដើម្បីអល់ឡោះជាកូនសោដ៏ឧត្តមនិងអស្ចារ្យដើម្បីបើកទទួលនូវភាពរីករាយ ភាពស្ងប់ស្ងាត់ និងពរជ័យសិរីសួស្តី។

អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលថា៖

ٱلَّذِينَ ءَامَنُواْ وَتَطۡمَئِنُّ قُلُوبُهُم بِذِكۡرِ ٱللَّهِۗ أَلَا بِذِكۡرِ ٱللَّهِ تَطۡمَئِنُّ ٱلۡقُلُوبُ

الرعد: ٢٨

មានន័យថា៖ «ពួកអ្នកមានជំនឿមានចិត្តស្កប់ស្កល់ដោយការសូត្រធម៌រំឭកចំពោះអល់ឡោះជាម្ចាស់។ ព្រោះ ការសូត្រធម៌រំឭកចំពោះអល់ឡោះធ្វើឱ្យចិត្តទទួលបាននូវភាពស្ងប់ស្កប់ស្កល់»។

ទ្រង់បានមានព្រះបន្ទូលទៀតថា៖

وَقَالَ رَبُّكُمُ ٱدۡعُونِيٓ أَسۡتَجِبۡ لَكُمۡ غافر: ٦٠

មានន័យថា: «ព្រះជាម្ចាស់របស់ពួកអ្នកបានមានព្រះបន្ទូលថា ចូរបួងសួងចំពោះយើងចុះ យើងនឹងទទួលយកការបួងសួងរបស់ពួកអ្នក»។

## 3. ហ្សាកាត់៖



ការបង់ហ្សាកាត់ជាកាតព្វកិច្ចសម្រាប់ចែកជូនដល់អ្នកទីទ័លក្រ។ ពិតណាស់ ការផ្តល់ហ្សាកាត់និងធ្វើទានចំពោះអ្នកក្រខ្វះខាតជួយជម្រះសម្អាតចិត្តពីភាពរិះកំណាញ់។

ហ្សាកាត់ជួយសម្អាតទ្រព្យសម្បត្តិ និងលុយកាក់របស់យើង បង្រៀនឱ្យយើងចេះយកចិត្តទុកដាក់ និងរួមចំណែកកសាងស្ពានមេត្រីភាពដ៏រឹងមាំនៃសេចក្តីស្រលាញ់ សេចក្តីគោរពទៅវិញទៅមករវាងអ្នកមាននិងអ្នកក្រ។ តាមពិត ហ្សាកាត់ជួយផ្សព្វផ្សាយបំផុសការចេះជួយគ្នា សាមគ្គីគ្នាជាធ្លុងមួយ មានភារតភាពនឹងគ្នាក្នុងសង្គមទាំងមូល។

## 4. បួស៖



បួស ឬការតមអាហារ ការហូបចុក និងការរួមដំណេកក្នុងចន្លោះពេលកំណត់មួយ ជាក់លាក់ចាប់ពីពេលអារុណរះ...



...រហូតដល់ថ្ងៃលិច។

ខាងក្រោមនេះជាសារប្រយោជន៍ខ្លះ និងគំនិតអប់រំដ៏ប្រពៃនៃការបួស៖

❖ **ផលប្រយោជន៍ផ្លូវចិត្ត**

បួសជួយបង្កើនភាពកោតខ្លាច និងសេចក្ដីជ្រះថ្លាចំពោះអល់ឡោះ។ ប្រាកដណាស់ ខែបួស (រ៉ម៉ាហ្ទន) ជារដូវដ៏ឧត្ដមដើម្បីទទួលបាននូវក្ដីមេត្តាករុណា ការខន្ដីអភ័យអំពីអល់ឡោះ ការសង្គ្រោះពីភ្លើងនរក និងទទួលបាននូវជីវិតអមតៈគឺឋានសួគ៌។

### ❖ ផលប្រយោជន៍ខាងសីលធម៌ និងផ្លូវកាយ

ក្នុងសាលារ៉ម៉ាហ្ទន (បួស) ធ្វើឱ្យយើងភ្លក់នូវរសជាតិនៃភាពអត់ឃ្លាន ការស្រេកទឹក ដែលមានមនុស្សរាប់លាននាក់កំពុងរងគ្រោះក្នុងពិភពលោកទាំងមូល។ បួសជំរុញឱ្យយើងចេះរួមចំណែក ចែករំលែកទាំងទឹកចិត្តនិងទ្រព្យសម្បត្តិដល់អ្នកដទៃ អាណិតអាសូរ និងមានចិត្តសប្បុរសចំពោះមនុស្សជាតិ។

### ❖ ផលប្រយោជន៍ខាងអប់រំ

បួសបង្រៀនយើងនូវមេរៀនអប់រំជាច្រើនដូចជា បង្រៀនយើងឱ្យកែប្រែទម្លាប់អាក្រក់ ឬបោះបង់ទម្លាប់នោះចោល ដូចជាការហូបចំណីដោយខ្ជះខ្ជាយ ហាត់ពត់លត់ដំខ្លួនឱ្យចេះអត់ធ្មត់ ខាំមាត់សង្កត់ចិត្ត។ ម្យ៉ាងទៀត បួសបង្រៀនយើងឱ្យដឹងថា ពួកព្យាការីរបស់អល់ឡោះដូចជា មូហាំម៉ាត់ មូសា និងអ៊ីសា ពួកគាត់សុទ្ធតែធ្លាប់បានបួសដូចយើងដែរ។

### ❖ ផលប្រយោជន៍ផ្នែកសុខភាព

តាមរយៈការបួស ខ្លួនប្រាណយើងនឹងជម្រះសម្អាតពីជាតិខ្លាញ់លើសកម្រិត សារជាតុពុល ហើយពួកវេជ្ជបណ្ឌិត ពួកអ្នកជំនាញបានណែនាំឱ្យយើងបួស។ ពួកគេបានហៅការបួសថា ជាការដុត

ចំហេះកាកសំណល់ ឬព្យាបាលបង្ការទុកជាមុន។ ពិតប្រាកដ បួសជាវិធីព្យាបាលថ្មីសម្រាប់ជំងឺជាច្រើន។

## 5. ការធ្វើធម្មយាត្រា (បុណ្យហ័ជ្ជ)

ការចេញដំណើរទៅកាន់មឹក្កះក្នុងបំណងបំពេញពិធីបុណ្យហ័ជ្ជដែលជាកាតព្វកិច្ចរបស់អ្នកមូស្លីមគ្រប់រូបត្រូវធ្វើឱ្យបានម្តងក្នុងមួយជីវិត(បុណ្យហ័ជ្ជកាតព្វកិច្ច) បើសិនមានលទ្ធភាពអាចបំពេញតាមលក្ខខណ្ឌ សុខភាព ទ្រព្យសម្បត្តិ និងមានបញ្ញាពេញលេញ។

ប្រាកដណាស់ សោភ័ណភាព តម្លៃ មេរៀន និងផលប្រយោជន៍នៃពិធីបុណ្យហ័ជ្ជមានច្រើនឥតគណនា។ ជាក់ស្តែង មានមូស្លីមរាប់លាននាក់ (ជាតិសាសន៍ ពណ៌សម្បុរ ប្រទេសផ្សេងៗគ្នាជុំវិញពិភពលោក)កំពុងឆ្លើយតបនឹងការអំពាវនាវរបស់ព្យាការីអ៊ីព្រហ៊ីម។

នៅមានគោលការណ៍ និងគោលគំនិតពិសេសៗមួយចំនួនជាគំរូដែលអ្នកនឹងបានឃើញនៅក្នុងពិធីនេះដូចជា ជំនឿលើព្រះតែមួយ ការគោរពប្រណិប័តន៍ និងការប្រតិបត្តិចំពោះអល់ឡោះ ភាតរភាពក្នុងឥស្លាម ឯកភាពជាតិឥស្លាម ការអត់ធ្មត់ ការលះបង់ ការថ្វាយបង្គំ ការធ្វើទាន ការបួស។ល។ ជាការពិត រដូវបុណ្យហ័ជ្ជគេឃើញថា ជា

សន្និសីទសាសនាដ៏ធំបំផុត ជាការជួបជុំផ្នែកសាសនាដ៏ធំបំផុតមានតែមួយគត់ក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ។

នៅក្នុងជំនួបដ៏ឧត្តមនេះ គ្រប់ជាតិសាសន៍ គ្រប់ជនជាតិទាំងអស់ប្រារព្ធការសក្ការៈថ្វាយចំពោះព្រះជាម្ចាស់តែមួយគត់ ហើយប្រតិបត្តិតាមសារតែមួយគត់។ លោក ម៉ាលកុម អិច និងអ្នកដទៃទៀតបានស្វែងយល់ និងរកឃើញពីសោភ័ណភាពនៃជំនឿដ៏ត្រឹមត្រូវ និងភាតរភាព ហើយនិងសមភាពក្នុងឥស្លាមនៅពេលដែលពួកគេបានទៅប្រារព្ធពិធីបុណ្យហ័ជ្ជនៅមឹក្កះ។

លោក ម៉ាល់កុម អិច (ជាមេទ័ពអាមេរិកស្បែកខ្មៅម្នាក់) បាននិយាយថា «ពិតណាស់ បុណ្យហ័ជ្ជរបស់ខ្ញុំធ្វើឱ្យគំនិត និងការយល់ដឹងរបស់ខ្ញុំបើកទូលាយ។ ក្នុងរយៈពេលតែពីរសប្ដាហ៍ប៉ុណ្ណោះក្នុងទឹកដីពិសិដ្ឋធ្វើឱ្យខ្ញុំមានការយល់ដឹងថ្មី។ ខ្ញុំបានឃើញអ្វីដែលខ្ញុំមិនធ្លាប់ឃើញក្នុងរយៈពេល៣៩ឆ្នាំនៅអាមេរិក។ ពិតណាស់ ខ្ញុំបានឃើញគ្រប់ជាតិសាសន៍ គ្រប់ជនជាតិ គ្រប់ពណ៌សម្បុរទាំងអស់ពួកគេឋិតក្នុងភាពជាបងប្អូននឹងគ្នាយ៉ាងពិតប្រាកដ។ មានឯកភាពពិតប្រាកដ ពួកគេរស់នៅដូចជាខ្លួនតែមួយ ពួកគេគោរពសក្ការៈចំពោះអល់ឡោះស្មើៗគ្នាដូចជាខ្លួនតែមួយ»។

# ជំពូកទី៣

## សោភ័ណភាព និងភាពបរិសុទ្ធនៃគម្ពីរអាល់គួរអាន

គម្ពីរអាល់គួរអានជាធម្មនុញ្ញដែលអល់ឡោះជាម្ចាស់ទ្រង់បានត្រាស់បន្ទូលមកដើម្បីរៀបចំ និងគ្រប់គ្រងជីវិតមនុស្ស។ គម្ពីរនេះបង្ហាញពីសច្ចភាព អំពាវនាវមនុស្សទៅកាន់ផ្លូវត្រូវ។ គម្ពីរនេះមាននិយាយអំពីជំណឹងផ្សេងៗ ចំណេះដឹងអំពីមនុស្សលោក និងវាសនារបស់ពួកគេ។

ពិតប្រាកដ គម្ពីរអាល់គួរអានបង្រៀន និងលើកកម្ពស់មនុស្សទៅកាន់កម្រិតនៃជំនឿមួយដ៏ខ្ពង់ខ្ពស់ សីលធម៌ឧត្តុង្គឧត្តម បញ្ញាមុតថ្លា និងសង្គមមួយថ្កុំថ្កើង ដរាបណាពួកគេអនុវត្តតាមគោលការណ៍ប្រព័ន្ធគ្រប់គ្រង និងពាក្យប្រៀនប្រដៅរបស់គម្ពីរនេះ។ អាល់គួរអានជាគម្ពីរអច្ឆរិយអមតៈដែលគេប្រទានជូនដល់ព្យាការីចុងក្រោយបង្អស់មូហាំម៉ាត់ជាភស្តុតាងបញ្ជាក់ពីភាពក្លាយជាព្យាការីរបស់គាត់។ អាល់គួរអានជាគម្ពីរច្បាប់ដើមតែមួយគត់គ្មានការកែប្រែ។ ថ្វីបើគម្ពីរនេះគេត្រាស់បន្ទូលមកកាន់ព្យាការីមូហាំម៉ាត់តាំងពី១៤សតវត្សកន្លងមក តែ

នៅរក្សាដូចច្បាប់ដើមដដែល គ្មានការកែប្រែ ទាំងសំណេរ និងខ្លឹមសាររបស់វាជាមាតុភាសាអារ៉ាប់។

ទិសដៅសំខាន់នៃគម្ពីរនេះគឺផ្តល់ជាឧទាហរណ៍គំរូខ្លះពីសោភ័ណភាព គោលការណ៍ និងមូលដ្ឋានគ្រឹះនៃឥស្លាម។ ខ្ញុំមិននិយាយពីប្រវត្តិ និងសុក្រឹតភាពនៃគម្ពីរអាល់គួរអាន (រឿងក្រែប្រែ ឬក្លែងបន្លំ)នោះទេ ព្រោះគម្ពីរនេះជាវ៉ះហ៊ី (ពាក្យបន្ទូលរបស់ព្រះ) ចុងក្រោយបង្អស់ដែលបានត្រាស់បង្គាប់ចំពោះព្យាការីមូហាំម៉ាត់។

ខ្ញុំមានបំណងចង់បង្ហាញពីវាក្យខណ្ឌមួយចំនួនដ៏មានសោភ័ណភាពនៃពាក្យបន្ទូលរបស់អល់ឡោះ និងជាគតិបណ្ឌិតរបស់ទ្រង់។ ខ្ញុំពិតជាមានកង្វល់ថា គួរជ្រើសរើសវាក្យខណ្ឌណាមួយមកបង្ហាញនៅទីនេះ។ ការជ្រើសរើសពិតជាមានការលំបាក សម្រាប់ទំព័រសៀវភៅដ៏តូចស្តួចស្តើង និងមានកំណត់នេះ។

បើសិនជាអ្នកពេញចិត្តចង់ស្វែងយល់បន្ថែមជុំវិញព្រះបន្ទូលដ៏មានសោភ័ណភាពរបស់អល់ឡោះ និងបរិសុទ្ធនោះ ចូរអាន ឬសូត្រគម្ពីរអាល់គួរអានដោយខ្លួនឯង (ជាលក្ខណៈបុគ្គលផ្ទាល់ខ្លួន)។

## វាក្យខណ្ឌគម្ពីរដ៏មានសោភ័ណភាព

ជាការពិត វាក្យខណ្ឌគម្ពីរអាល់គួរអានជាពាក្យបន្ទូលរបស់អល់ឡោះ យើងនាំគ្នាសូត្រ និងស្ដាប់មាត្រាដ៏ប្រពៃមួយចំនួននៃគម្ពីរអាល់គួរអានដែលបញ្ជាក់ពីទន្សនៈឥស្លាមឆ្លើយតបនឹងការយល់ដឹង និងសំណួរសំខាន់ៗមួយចំនួន។

## ការសង្គ្រោះ និងការអភ័យទោស

﴿ قُلْ يَٰعِبَادِىَ ٱلَّذِينَ أَسْرَفُوا۟ عَلَىٰٓ أَنفُسِهِمْ لَا تَقْنَطُوا۟ مِن رَّحْمَةِ ٱللَّهِ ۚ إِنَّ ٱللَّهَ يَغْفِرُ ٱلذُّنُوبَ جَمِيعًا ۚ إِنَّهُۥ هُوَ ٱلْغَفُورُ ٱلرَّحِيمُ ﴿٥٣﴾ ﴾ الزمر: ٥٣

មានន័យថា៖ «មូហាំម៉ាត់ចូរមានប្រសាសន៍ចុះថា នែខ្ញុំបម្រើរបស់យើងដែលជ្រុលខ្លួនប្រព្រឹត្តល្មើស ចូរកុំអស់សង្ឃឹមចំពោះក្ដីមេត្តារបស់អល់ឡោះ។ ពិតប្រាកដ អល់ឡោះទ្រង់អភ័យនូវរាល់អំពើបាបទាំងឡាយ។ ពិតប្រាកដ ទ្រង់មហាអភ័យ មហាមេត្តា»។

ពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់អភ័យនូវរាល់អំពើបាបទាំងអស់ នៅពេលដែលយើងត្រឡប់ទៅរកទ្រង់ដោយការសារភាពកំហុសដោយស្មោះត្រង់។ ប្រាកដណាស់ ទ្រង់ប្រទានដល់ខ្ញុំបម្រើ

របស់ទ្រង់នូវការទទួលយកការបួងសួង និងការខន្តីអភ័យទោស។ ពិតប្រាកដ អល់ឡោះជាម្ចាស់ក្នុងឥស្លាម ទ្រង់ជាប្រភពនៃសន្តិភាព ក្តីមេត្តាករុណា ការខន្តីអភ័យទោស តែទ្រង់ពុំមែនជាប្រភពនៃទោសៈ ការបង្ខំរឈាម និងអំពើភេរវកម្មនោះទេ។

﴿ إِنَّ ٱللَّهَ يُحِبُّ ٱلتَّوَّٰبِينَ وَيُحِبُّ ٱلۡمُتَطَهِّرِينَ ٢٢٢ ﴾ البقرة: ٢٢٢

មានន័យថា៖ «ពិតណាស់ អល់ឡោះទ្រង់សព្វព្រះទ័យចំពោះពួកអ្នកសារភាពកំហុស ហើយទ្រង់សព្វព្រះទ័យចំពោះពួកអ្នកដែលស្អាតស្អំ»។

ក្នុងសាសនាឥស្លាម បើសិនជាអ្នកចង់ទទួលបានការសង្គ្រោះ និងជីវិតអមតៈគឺអ្នកអាចទទួលបានដោយងាយស្រួល ដោយគ្រាន់តែវិលត្រឡប់ទៅរកទ្រង់ មានជំនឿចំពោះទ្រង់តែមួយគត់ ប្រតិបត្តិអំពើល្អ ពុំបាច់ឆ្ពាង ឬសម្លាប់បុគ្គលល្អដើម្បីលុបលាងអំពើបាបដែលប្រព្រឹត្តដោយអ្នកដទៃនោះឡើយ។

នេះគឺជាគោលការណ៍ដ៏មានសោភ័ណភាពអំពីការសង្គ្រោះ និងការលើកលែងទោសក្នុងឥស្លាម។ សង្ខេបមកវិញ ឥស្លាមគឺជាសាសនានៃក្តីមេត្តា និងការខន្តីអភ័យទោស។

## យុត្តិធម៌៖

﴿ يَٰٓأَيُّهَا ٱلَّذِينَ ءَامَنُوا۟ كُونُوا۟ قَوَّٰمِينَ لِلَّهِ شُهَدَآءَ بِٱلْقِسْطِ ۖ وَلَا يَجْرِمَنَّكُمْ شَنَـَٔانُ قَوْمٍ عَلَىٰٓ أَلَّا تَعْدِلُوا۟ ۚ ٱعْدِلُوا۟ هُوَ أَقْرَبُ لِلتَّقْوَىٰ ۖ وَٱتَّقُوا۟ ٱللَّهَ ۚ إِنَّ ٱللَّهَ خَبِيرٌۢ بِمَا تَعْمَلُونَ ﴿٨﴾ ﴾ المائدة: ٨

មានន័យថា៖ «ម្នាលពួកអ្នកមានជំនឿទាំងឡាយចូរតាំងខ្លួនប្រកាន់នូវសច្ចភាពដោយចិត្តជ្រះថ្លាចំពោះអល់ឡោះ ជាកសិនសាក្សីដែលប្រកបដោយយុត្តិធម៌ កុំប្រកាន់នឹងកំហឹងរបស់មនុស្សមួយចំនួនធ្វើឱ្យពួកអ្នកប្រាសចាកពីភាពយុត្តិធម៌។ ចូរប្រកាន់ចុះនូវភាពយុត្តិធម៌ ព្រោះវាខិតជិតបំផុតទៅរកភាពកោតខ្លាចចំពោះអល់ឡោះ។ ចូរកោតខ្លាចចំពោះអល់ឡោះ និងប្រុងប្រយ័ត្នកុំប្រើប្រជាហិង្ស។ ប្រាកដណាស់ អល់ឡោះទ្រង់ដឹងល្អិតល្អន់ពីអ្វីដែលពួកអ្នកធ្វើ»។

ពិតណាស់ ឥស្លាមបង្រៀនយើងឱ្យក្លាយជាបុគ្គលដែលប្រកាន់នូវភាពយុត្តិធម៌ចំពោះមនុស្សទូទៅ សូម្បីតែជាមិត្តភក្តិ ឬសត្រូវ ក្នុងគ្រប់កាលៈទេសៈ ទាំងពេលមានសន្តិភាព ឬពេលមានសង្គ្រាម។

ឥស្លាមបង្រៀនសាសនិករបស់ខ្លួនឱ្យដើរតាមផ្លូវយុត្តិធម៌ សីលធម៌ ដោយគ្មានលក្ខខណ្ឌ ជ្រះស្អាតពីកត្តានយោបាយ មនោសញ្ចេតនាបុគ្គល ផ្នត់គំនិតសង្គម និងវប្បធម៌។

﴿ إِنَّ ٱللَّهَ يَأۡمُرُكُمۡ أَن تُؤَدُّواْ ٱلۡأَمَٰنَٰتِ إِلَىٰٓ أَهۡلِهَا وَإِذَا حَكَمۡتُم بَيۡنَ ٱلنَّاسِ أَن تَحۡكُمُواْ بِٱلۡعَدۡلِۚ إِنَّ ٱللَّهَ نِعِمَّا يَعِظُكُم بِهِۦٓۗ إِنَّ ٱللَّهَ كَانَ سَمِيعَۢا بَصِيرٗا ﴿٥٨﴾ ﴾ النساء: ٥٨

មានន័យថា៖ «ពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់បង្គាប់ពួកអ្នកឱ្យបំពេញសេចក្តីទុកចិត្តជូនម្ចាស់ដើមគេវិញ ហើយនៅពេលណាពួកអ្នកកាត់ក្តីរវាងមនុស្សលោក ចូរកាត់ក្តីដោយយុត្តិធម៌។ នេះគឺការទូន្មានដាស់រំឭកដ៏ប្រពៃបំផុតរបស់អល់ឡោះចំពោះពួកអ្នក។ ជាការពិតណាស់ អល់ឡោះទ្រង់មហាលឺ មហាឃើញ»។

ដើម្បីបញ្ជាក់ពីការអនុវត្តពិតជាក់ស្តែងសម្រាប់សោភ័ណភាព តម្លៃដ៏អមតៈ ក្តីមេត្តា និងភាពយុត្តិធម៌នៃឥស្លាម យើងគប្បីរក្សានូវអ្វីដែលវិទូឥស្លាមបានហៅថា កត្តាចាំបាច់ទាំងប្រាំ។

ឥស្លាមប្រើឱ្យពួកអ្នកមូស្លីមរក្សាសិទ្ធិរបស់ខ្លួន និងសិទ្ធិរបស់អ្នកដទៃទាក់ទងនឹងកត្តាចាំបាច់ទាំងប្រាំគឺ៖

១. សាសនា

២. ជីវិត

៣. ប្រាជ្ញា

៤. កិត្តិយស

៥. ទ្រព្យសម្បត្តិ

ពិតណាស់ គម្ពីរអាល់គួរអានបញ្ជាក់យ៉ាងច្បាស់ថា នរណាសម្លាប់ជីវិតដែលគ្មានទោសនោះ ហាក់បីដូចជា

﴿ فَكَأَنَّمَا قَتَلَ ٱلنَّاسَ جَمِيعًا وَمَنْ أَحْيَاهَا فَكَأَنَّمَآ أَحْيَا ٱلنَّاسَ جَمِيعًا ﴾ المائدة: ٣٢

មានន័យថា៖ «ហាក់បីដូចជាគេសម្លាប់មនុស្សទាំងមូល ហើយនរណាបដិសេធមិនសម្លាប់ជីវិតមនុស្សម្នាក់ដែលគ្មានទោស ហាក់បីដូចជាគេរក្សាជីវិតរបស់មនុស្សទាំងមូល»។

ទាក់ទងនឹងសិទ្ធិសេរីភាព និងការការពារសិទ្ធិនៃជំនឿ គម្ពីរអាល់គួរអានបានចែងថា៖

﴿ لَآ إِكْرَاهَ فِى ٱلدِّينِ ﴾ البقرة: ٢٥٦

មានន័យថាៈ «គ្មានការបង្ខិបង្ខំជាដាច់ខាតក្នុងសាសនា»។

បែបនេះឯង ឥស្លាមបានផ្ដល់តម្លៃដល់មនុស្សលោក មិនបង្ខិតបង្ខំនរណាម្នាក់ឱ្យកាន់តាមជំនឿឥស្លាមនោះឡើយ។

នេះគឺជាធាតុពិតនៃឥស្លាម មានសោភ័ណភាព យុត្តិធម៌ និងក្ដីមេត្តាក្នុងការប្រាស្រ័យទាក់ទងជាមួយនឹងអ្នកមិនមែនឥស្លាម។

ដូច្នេះ ជាការចាំបាច់ យើងទាំងអស់គ្នាត្រូវប្រកាន់ពាក្យសច្ចៈមានហេតុផល ប្រកាន់នូវភាពយុត្តិធម៌ក្នុងការវិនិច្ឆ័យចំពោះអ្នកដទៃ។ យើងនាំគ្នារំឭកឡើងវិញពីពាក្យបន្ទូលរបស់អល់ឡោះក្នុងគម្ពីរអាល់គួរអានថា៖

﴿وَلَا يَجۡرِمَنَّكُمۡ شَنَـَٔانُ قَوۡمٍ عَلَىٰٓ أَلَّا تَعۡدِلُواْۚ ٱعۡدِلُواْ هُوَ أَقۡرَبُ لِلتَّقۡوَىٰ﴾ المائدة: ٨

មានន័យថា៖ «កុំប្រកាន់នឹងកំហឹងរបស់មនុស្សមួយចំនួនធ្វើឱ្យពួកអ្នកប្រាសចាកពីភាពយុត្តិធម៌។ ចូរប្រកាន់នូវភាពយុត្តិធម៌ចុះ ព្រោះវាខិតជិតបំផុតទៅរកភាពកោតខ្លាចចំពោះអល់ឡោះ»។

ចំពោះពួកអ្នកនិពន្ធ ពួកប្រវត្តិវិទូ ពួកអ្នកសារព័ត៌មានប្រើពាក្យភេរវកម្មចោទប្រកាន់សាសនាឥស្លាម និងពួកអ្នកមូស្លីមដោយអយុត្តិធម៌នោះ ពួកគេផ្សព្វផ្សាយមួលបង្កាច់ថា ឥស្លាមពង្រីកអាណា

ចក្ររបស់ខ្លួនដោយផ្លែដាវ និងកម្លាំងអំណាច។ ទាំងនោះគឺជាពួកអ្នកដែលបញ្ញាញាណរបស់ពួកគេមានជំងឺ និងចិត្តរបស់ពួកមានបញ្ហា ពួកគេបានគូសរូបតុ្តករបស់អល់ឡោះជាម្ចាស់ និងព្យាការីមូហាំម៉ាត់ ហើយជារូបកំប្លុកកំប្លែងដ៏អាក្រក់ និងគួរឱ្យអាម៉ាស់ជាទីបំផុត។ ខ្ញុំសុំសួរដោយឆោតថា៖

- តើនេះគឺជាសិទ្ធិសេរីភាព និងជាសេរីភាពក្នុងការបញ្ចេញមតិឬ? តើនេះពុំមែនជាល្បិចកលដើម្បីប្រមាថមើលងាយដល់សាសនាឥស្លាម និងពួកអ្នកមូស្លីមទេឬ?
- តើនរណាម្នាក់មានសិទ្ធិសេរីភាពក្នុងការដាក់បណ្តាសា ជេរប្រមាថ និងមើលងាយអ្នកដទៃ និងជំនឿរបស់ពួកគេ? ឬចោទពួកគេទាំងអស់ដោយពាក្យភេរវកម្ម និងការកាប់សម្លាប់?
- តើនេះឬជាអរិយធម៌ លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិសេរីភាពដែលបានបង្រៀនយុវជនជំនាន់ក្រោយនៅតាមសាលា សាកលវិទ្យាល័យ និងសង្គមរបស់ពួកគេជាទូទៅ?
- តើដោយផ្លែដាវឥស្លាមឬដែលធ្វើឱ្យមនុស្សរាប់ពាន់នាក់ទាំងប្រុសទាំងស្រី ពួកអ្នកប្រាជ្ញ (ដោយមានហេតុផល ភាពស្មោះ

ត្រង់ បើកចិត្តទូលាយជុំវិញពិភពលោក)បានចូលសាសនាឥស្លាមក្នុងពេលបច្ចុប្បន្ន?

(មានសៀវភៅ អត្ថបទ គេហទំព័រជាច្រើនបានចោទសួរថា ហេតុអ្វីបានជាបងប្អូនទាំងនោះវិលមករកសាសនាឥស្លាម)។

យោងតាមរបាយការណ៍អាមេរិក និងអឺរ៉ុបបានឱ្យដឹងថា ឥស្លាមជាសាសនាដែលរីកចម្រើន និងរីកសុសសាយឆាប់រហ័សជាងសាសនាណាៗទាំងអស់ក្នុងពិភពលោក។

# ដូច្នេះ ហេតុអ្វីក៏ជាឥស្លាមទៅវិញ?

# សមភាពក្នុងឥស្លាមៈ



﴿ يَٰٓأَيُّهَا ٱلنَّاسُ إِنَّا خَلَقۡنَٰكُم مِّن ذَكَرٖ وَأُنثَىٰ وَجَعَلۡنَٰكُمۡ شُعُوبٗا وَقَبَآئِلَ لِتَعَارَفُوٓاْۚ إِنَّ
أَكۡرَمَكُمۡ عِندَ ٱللَّهِ أَتۡقَىٰكُمۡۚ إِنَّ ٱللَّهَ عَلِيمٌ خَبِيرٞ ١٣ ﴾ الحجرات: ١٣

មានន័យថា៖ «ម្នាលមនុស្សទាំងឡាយ យើងបានបង្កើតពួកអ្នកពីបុរសម្នាក់ និងស្ត្រីម្នាក់ ហើយបង្កើតពួកអ្នកជាពូជសាសន៍ និងកុលសម្ព័ន្ធជាច្រើន ដើម្បីឱ្យពួកអ្នកស្គាល់គ្នា។ អ្នកដែលប្រសើរជាងគេក្នុងចំណោមពួកអ្នក ចំពោះអល់ឡោះគឺអ្នកដែលកោតខ្លាចជាងគេ។ ពិតណាស់ អល់ឡោះទ្រង់មហាដឹង មហាស្ទាត់ជំនាញ»។



ដើម្បីបញ្ជាក់ពីគោលការណ៍ដ៏ប្រពៃអំពីសមភាពក្នុងឥស្លាម ព្យាការីលោកបានមានប្រសាសន៍ក្នុងធម្មទេសនាលាដំណើរចុងក្រោយរបស់លោកថា៖

( يا أيها الناس ألا إن ربكم واحد وإن أباكم واحد إلا لا فضل لعربي على أعجمي ولا لعجمي على عربي ولا لأحمر على أسود ولا أسود على أحمر إلا بالتقوى ) مسند الإمام أحمد

មានន័យថា៖ «ម្នាលមនុស្សទាំងឡាយ តើមិនមែនទេឬ? ប្រាកដណាស់ ព្រះជាម្ចាស់របស់ពួកអ្នកគឺតែមួយ ឪពុករបស់ពួកអ្នកគឺតែមួយ។ តាមពិត គ្មាននរណាប្រសើរជាងនរណាឡើយ អារ៉ាប់មិនប្រសើរជាងសាសន៍ដទៃ ហើយសាសន៍ដទៃមិនប្រសើរជាងអារ៉ាប់ជនជាតិស្បែកសមិនប្រសើរជាងជនជាតិស្បែកខ្មៅ លើកលែងតែសេចក្ដីកោតខ្លាចតែប៉ុណ្ណោះ»។

*ឥស្លាមបង្រៀនយើងកុំឱ្យប្រមាថមើលងាយចំពោះអ្នកដទៃដោយផ្អែកលើមូលដ្ឋានជាតិសាសន៍ ពណ៌សម្បុរ ឬជនជាតិនោះទេ។ ឥស្លាមដោះស្រាយជាក់ស្ដែងចំពោះជម្លោះជាតិសាសន៍និយម ពូជសាសន៍និយមដែលពិភពលោកទាំងមូលកំពុងប្រឈមមុខ។*



ក្នុងឥស្លាម ស្បែកស និងស្បែកខ្មៅគ្រាន់តែជាបងប្អូន នឹងគ្នាចេញពីពូជមនុស្សដូចគ្នា ពួកគេទាំងអស់កើតពីឪពុកតែមួយគឺអាដាំដែលគេបង្កើតពីដី។ ដូច្នេះ មនុស្សទាំងអស់កើតចេញពីធាតុដី នឹងត្រឡប់ទៅក្នុងដី ហើយនឹងក្លាយជាដីម្តងទៀត។ ចុះហេតុអ្វីបានជាមនុស្សខ្លះមានអារម្មណ៍ក្រអឺតក្រទម និងមានអំណួតអួតអាង?




ឥស្លាមយកចិត្តទុកដាក់ចំពោះសមភាព និងការឱនលំទោន។ នេះគឺជាមេរៀនដ៏រីករាយដែលយើងដកស្រង់ចេញពីមាត្រាផ្សេងៗនៃគម្ពីរអាល់គួរអាន និងប្រសាសន៍របស់ព្យាការី។ ម្យ៉ាងទៀត ក៏ជាមេរៀន

ដែលលោក ម៉ាល់កុម អិច បានរៀន នៅពេលដែលលោកទៅបំពេញបុណ្យហាជ្ជនៅម៉ឹក្កះ។

## សកលនីយកម្ម និងភាពតែមួយនៃសារឥស្លាម

﴿ قُولُوٓاْ ءَامَنَّا بِٱللَّهِ وَمَآ أُنزِلَ إِلَيۡنَا وَمَآ أُنزِلَ إِلَىٰٓ إِبۡرَٰهِـۧمَ وَإِسۡمَٰعِيلَ وَإِسۡحَٰقَ وَيَعۡقُوبَ وَٱلۡأَسۡبَاطِ وَمَآ أُوتِيَ مُوسَىٰ وَعِيسَىٰ وَمَآ أُوتِيَ ٱلنَّبِيُّونَ مِن رَّبِّهِمۡ لَا نُفَرِّقُ بَيۡنَ أَحَدٖ مِّنۡهُمۡ وَنَحۡنُ لَهُۥ مُسۡلِمُونَ ١٣٦ ﴾ البقرة: ١٣٦

មានន័យថា៖ «ចូរពួកអ្នកពោលចុះថា ពួកយើងមានជំនឿចំពោះអល់ឡោះ និងអ្វីដែលគេបានប្រទានចុះមកចំពោះយើង និងប្រទានចុះមកដល់អ៊ីព្រហ៊ីម អ៊ិស្មាអែល អ៊ិស្ហាក យ៉ាក់កូប និងពួកព្យាការីដែលជាកូនចៅរបស់យ៉ាក់កូបនៃកុលសម្ព័ន្ធទាំង១២របស់សាសន៍អ៊ិស្រាអែល ហើយអ្វីដែលគេបានប្រទានចំពោះមូសា និងអ៊ីសា ព្រមទាំងអ្វីដែលគេបានប្រទានចំពោះពួកព្យាការីទូទៅអំពីព្រះជាម្ចាស់របស់ពួកគេ។ ពួកយើងមិនបែងចែកនរណាម្នាក់ក្នុងចំណោមពួកគេ ហើយពួកយើងជាពួកអ្នកគោរពប្រណិប័តន៍ចំពោះទ្រង់ (មូស្លីម)»។

ពិតណាស់ ពួកអ្នកមូស្លីមស្រឡាញ់គ្រប់ព្យាការីទាំងអស់របស់អល់ឡោះ និងពួកអ្នកនាំសាររបស់ទ្រង់ ហើយពួកគេជឿចំពោះពួកអ្នកនាំសារទាំងនោះរួមមាន អាដាំ ណួហ អ៊ីព្រហ៊ីម អ៊ិស្មាអែល អ៊ិស្ហាក យ៉ាក់កូប មូសា អ៊ីសា មូហាំម៉ាត់ ហើយព្យាការីមូហាំម៉ាត់លោកបានប្រសាសន៍ថា៖

قال رسول الله صلى الله عليه وسلم: ( أنا أولى الناس بعيسى بن مريم في الأولى والآخرة قالوا كيف ؟ يا رسول الله قال الأنبياء إخوة من علات وأمهاتهم شتى ودينهم واحد فليس بيننا نبي ) متفق عليه

មានន័យថា៖ « ខ្ញុំជាអ្នកដែលត្រូវជឿចំពោះអ៊ីសា កូននាងម៉ារី មុនគេបង្អស់ទាំងនៅលោកីយ៍នេះ និងនៅបរលោក។ ពួកគេសួរថា បពិត្រអ្នកនាំសារ តើជឿយ៉ាងដូចម្តេច? លោកតបវិញថា ពួកព្យាការីទាំងអស់ជាបងប្អូនមកពីគ្រួសារ និងម្តាយទីទៃពីគ្នា តែសាសនារបស់ពួកគេតែមួយ ហើយនៅចន្លោះពួកយើងទាំងពីរនាក់គ្មានព្យាការីឡើយ»។

ដូច្នេះ តើអ្វីជាសាសនាសកល និងតែមួយសម្រាប់ពួកព្យាការីទាំងអស់?

## វាក្យខណ្ឌផ្សេងទៀតដ៏មានសោភ័ណភាពសម្រាប់ត្រិះរិះពិចារណា៖

ពិតណាស់ សោភ័ណភាព ទឹកដមពីរោះ និងភាពបរិសុទ្ធនៃគម្ពីរអាល់គួរអានគ្មានដែនកំណត់នោះឡើយ។ ដូច្នេះ ខ្ញុំចង់បង្ហាញវាក្យខណ្ឌខ្លះនៃគម្ពីរអាល់គួរអានដោយគ្មានការបកស្រាយ តែខ្ញុំចង់ឱ្យអ្នកទាំងអស់គ្នាត្រិះរិះពិចារណាចំពោះវាក្យខណ្ឌទាំងនេះ ដើម្បីសិក្សាស្រាវជ្រាវបន្ថែមទៀតអំពីកំណប់នៃគម្ពីរអាល់គួរអាន។

### អល់ឡោះនិងអ្នកនាំសាររបស់ទ្រង់៖

﴿ هُوَ ٱلَّذِيٓ أَرۡسَلَ رَسُولَهُۥ بِٱلۡهُدَىٰ وَدِينِ ٱلۡحَقِّ ﴾ الفتح: ٢٨

មានន័យថា៖ «អល់ឡោះជាម្ចាស់ទ្រង់បានបញ្ជូនអ្នកនាំសាររបស់ទ្រង់ដោយសេចក្ដីចង្អុលបង្ហាញ និងសាសនាដ៏សច្ចៈ»។

﴿ مَّا كَانَ مُحَمَّدٌ أَبَآ أَحَدٖ مِّن رِّجَالِكُمۡ وَلَٰكِن رَّسُولَ ٱللَّهِ وَخَاتَمَ ٱلنَّبِيِّـۧنَۗ وَكَانَ ٱللَّهُ بِكُلِّ شَيۡءٍ عَلِيمٗا ٤٠ ﴾ الأحزاب: ٤٠

មានន័យថា៖ «មូហាំម៉ាត់ពុំមែនជាឪពុកនរណាម្នាក់ក្នុងចំណោមបុរសនៃពួកអ្នក តែគេជាអ្នកនាំសាររបស់អល់ឡោះ និងជា

ព្យាការីចុងក្រោយ ហើយអល់ឡោះជាម្ចាស់ទ្រង់តែងតែដឹងយ៉ាងច្បាស់លាស់នូវអ្វីគ្រប់យ៉ាង»។

## សេចក្ដីស្ងប់ និងឋានសួគ៌

﴿ هُوَ ٱلَّذِيٓ أَنزَلَ ٱلسَّكِينَةَ فِي قُلُوبِ ٱلۡمُؤۡمِنِينَ لِيَزۡدَادُوٓاْ إِيمَٰنٗا مَّعَ إِيمَٰنِهِمۡۗ وَلِلَّهِ جُنُودُ ٱلسَّمَٰوَٰتِ وَٱلۡأَرۡضِۚ وَكَانَ ٱللَّهُ عَلِيمًا حَكِيمٗا ۝٤ لِّيُدۡخِلَ ٱلۡمُؤۡمِنِينَ وَٱلۡمُؤۡمِنَٰتِ جَنَّٰتٖ تَجۡرِي مِن تَحۡتِهَا ٱلۡأَنۡهَٰرُ خَٰلِدِينَ فِيهَا وَيُكَفِّرَ عَنۡهُمۡ سَيِّـَٔاتِهِمۡۚ وَكَانَ ذَٰلِكَ عِندَ ٱللَّهِ فَوۡزًا عَظِيمٗا ۝٥ ﴾ الفتح: ٤ - ٥

មានន័យថា៖ «ទ្រង់ដែលបានប្រទានសេចក្ដីស្ងប់ក្នុងដួងចិត្តរបស់ពួកអ្នកមានជំនឿដើម្បីបន្ថែមជំនឿលើជំនឿរបស់ពួកគេ។ សម្រាប់អល់ឡោះទ្រង់មានពលរេហ៍នៅលើមេឃ និងលើដី ហើយអល់ឡោះជាម្ចាស់ទ្រង់មហាដឹងប្រកបដោយគតិបណ្ឌិត។ ដើម្បីឱ្យពួកអ្នកមានជំនឿប្រុសស្រីបានចូលឋានសួគ៌ដែលមានទន្លេហូរពីក្រោម ពួកគេរស់នៅក្នុងឋានសួគ៌នោះជាអមតៈ ទ្រង់លាងជម្រះពួកគេពីអំពើអាក្រក់ទាំងឡាយ។ នោះគឺជាភាពជោគជ័យដ៏ឧត្ដមបំផុតនៅចំពោះអល់ឡោះជាម្ចាស់»។

﴿ يَٰٓأَيَّتُهَا ٱلنَّفۡسُ ٱلۡمُطۡمَئِنَّةُ ﴿٢٧﴾ ٱرۡجِعِيٓ إِلَىٰ رَبِّكِ رَاضِيَةٗ مَّرۡضِيَّةٗ ﴿٢٨﴾ فَٱدۡخُلِي فِي عِبَٰدِي ﴿٢٩﴾ وَٱدۡخُلِي جَنَّتِي ﴿٣٠﴾ ﴾الفجر: ٢٧ - ٣٠

មានន័យថា៖ «ឱជីវិតដែលមានសេចក្តីស្ងប់ ចូរវិលត្រឡប់មករកព្រះជាម្ចាស់ដោយពេញចិត្តនឹងសេចក្តីប្រទានរបស់អល់ឡោះ។ ចូរចូលក្នុងចំណោមពួកខ្ញុំបម្រើរបស់យើង ហើយចូរចូលឋានសួគ៌របស់យើងចុះ»។

## បុរសនិងស្ត្រី

﴿ إِنَّ ٱلۡمُسۡلِمِينَ وَٱلۡمُسۡلِمَٰتِ وَٱلۡمُؤۡمِنِينَ وَٱلۡمُؤۡمِنَٰتِ وَٱلۡقَٰنِتِينَ وَٱلۡقَٰنِتَٰتِ وَٱلصَّٰدِقِينَ وَٱلصَّٰدِقَٰتِ وَٱلصَّٰبِرِينَ وَٱلصَّٰبِرَٰتِ وَٱلۡخَٰشِعِينَ وَٱلۡخَٰشِعَٰتِ وَٱلۡمُتَصَدِّقِينَ وَٱلۡمُتَصَدِّقَٰتِ وَٱلصَّٰٓئِمِينَ وَٱلصَّٰٓئِمَٰتِ وَٱلۡحَٰفِظِينَ فُرُوجَهُمۡ وَٱلۡحَٰفِظَٰتِ وَٱلذَّٰكِرِينَ ٱللَّهَ كَثِيرٗا وَٱلذَّٰكِرَٰتِ أَعَدَّ ٱللَّهُ لَهُم مَّغۡفِرَةٗ وَأَجۡرًا عَظِيمٗا ﴿٣٥﴾ ﴾الأحزاب: ٣٥

មានន័យថា៖ «ប្រាកដណាស់ ពួកអ្នកមូស្លីមប្រុសស្រីដែលមានជំនឿ គោរពប្រណិប័តន៍ ស្មោះត្រង់ អត់ធ្មត់ មានជំនឿស៊ប់

ធ្វើទាន បួស រក្សាភាពបរិសុទ្ធ និងពួកអ្នកដែលចម្រើននូវការសូត្រធម៌រំឭកអល់ឡោះ អល់ឡោះទ្រង់រៀបចំត្រៀមរួចជាស្រេចសម្រាប់ពួកគេនូវផលបុណ្យដ៏ឧត្តុង្គឧត្តម»។

﴿ وَمَن يَعۡمَلۡ مِنَ ٱلصَّٰلِحَٰتِ مِن ذَكَرٍ أَوۡ أُنثَىٰ وَهُوَ مُؤۡمِنٞ فَأُوْلَٰٓئِكَ يَدۡخُلُونَ ٱلۡجَنَّةَ وَلَا يُظۡلَمُونَ نَقِيرٗا ﴿١٢٤﴾ ﴾النساء: ١٢٤

មានន័យថា៖ «នរណាប្រតិបត្តិអំពើល្អ ទោះបុរស ឬស្ត្រី ហើយគេជាអ្នកមានជំនឿ នោះគឺជាពួកអ្នកដែលបានចូលឋានសួគ៌ ហើយគ្មាននរណាកេងប្រវ័ញ្ចគេសូម្បីប៉ុនស្នាមចង្អូរគ្រាប់ធញ្ញជាតិ»។

## ជាគោលការណ៍ដ៏ឧត្តុង្គឧត្តម៖

﴿ وَسَارِعُوٓاْ إِلَىٰ مَغۡفِرَةٖ مِّن رَّبِّكُمۡ وَجَنَّةٍ عَرۡضُهَا ٱلسَّمَٰوَٰتُ وَٱلۡأَرۡضُ أُعِدَّتۡ لِلۡمُتَّقِينَ ﴿١٣٣﴾ ٱلَّذِينَ يُنفِقُونَ فِي ٱلسَّرَّآءِ وَٱلضَّرَّآءِ وَٱلۡكَٰظِمِينَ ٱلۡغَيۡظَ وَٱلۡعَافِينَ عَنِ ٱلنَّاسِۗ وَٱللَّهُ يُحِبُّ ٱلۡمُحۡسِنِينَ ﴿١٣٤﴾ وَٱلَّذِينَ إِذَا فَعَلُواْ فَٰحِشَةً أَوۡ ظَلَمُوٓاْ أَنفُسَهُمۡ ذَكَرُواْ ٱللَّهَ فَٱسۡتَغۡفَرُواْ لِذُنُوبِهِمۡ وَمَن يَغۡفِرُ ٱلذُّنُوبَ إِلَّا ٱللَّهُ وَلَمۡ يُصِرُّواْ عَلَىٰ مَا فَعَلُواْ وَهُمۡ يَعۡلَمُونَ ﴿١٣٥﴾ أُوْلَٰٓئِكَ

﴿جَزَآؤُهُم مَّغۡفِرَةٞ مِّن رَّبِّهِمۡ وَجَنَّٰتٞ تَجۡرِي مِن تَحۡتِهَا ٱلۡأَنۡهَٰرُ خَٰلِدِينَ فِيهَاۚ وَنِعۡمَ أَجۡرُ ٱلۡعَٰمِلِينَ ١٣٦﴾ آل عمران: ١٣٣ - ١٣٦

មានន័យថា៖ «ចូរពួកអ្នកប្រញាប់ប្រួសរាន់ទៅរកការខន្តីអភ័យទោសពីព្រះជាម្ចាស់របស់ពួកអ្នក និងឋានសួគ៌ដែលមានទំហំប៉ុនមេឃនិងផែនដី គេរៀបចំត្រៀមសម្រាប់ពួកអ្នកដែលកោតខ្លាច។ ពួកអ្នកដែលចំណាយទ្រព្យសម្បត្តិទាំងពេលសុខស្រួល និងពេលលំបាក ពួកអ្នកចេះទប់កំហឹងដោយការអត់ធ្មត់ និងពួកអ្នកដែលចេះអត់ឱនដល់មនុស្សលោក ហើយអល់ឡោះសព្វព្រះទ័យចំពោះពួកអ្នកដែលធ្វើល្អ។ ពួកអ្នកដែលនៅពេលណាខ្លួនគេប្រព្រឹត្តអំពើអបាយមុខ ឬអំពើបាបផ្សេងៗដោយអគតិនោះ ពួកគេនឹកឃើញការសន្យារបស់អល់ឡោះ ហើយសារភាពកំហុសនិងសុំអភ័យទោសពីទ្រង់ចំពោះអំពើបាបរបស់ពួកគេ។ តើមាននរណាលើកលែងទោសក្រៅពីអល់ឡោះ? ពួកគេមិនចចេសរឹងរូសលើអំពើដែលពួកគេបានប្រព្រឹត្ត ហើយពួកគេដឹងថា បើសិនជាខ្លួនសារភាពកំហុសនោះទ្រង់នឹងទទួលយក។ ទាំងនោះគឺជាពួកអ្នកដែលទទួលបាននូវការខន្តីអភ័យទោសពីព្រះជាម្ចាស់របស់ពួកគេ និងឋានសួគ៌ដែលមានទន្លេហូរពីក្រោម។

ពួកគេរស់នៅជាអមតៈក្នុងឋានសួគ៌នោះ ហើយជាផលបុណ្យដ៏ប្រសើរជាទីបំផុតសម្រាប់ពួកអ្នកដែលប្រតិបត្តិ»។

## បទបញ្ជានិងបម្រាម៖

﴿ لَا تَعْبُدُونَ إِلَّا ٱللَّهَ وَبِٱلْوَٰلِدَيْنِ إِحْسَانًا وَذِى ٱلْقُرْبَىٰ وَٱلْيَتَـٰمَىٰ وَٱلْمَسَـٰكِينِ وَقُولُوا۟ لِلنَّاسِ حُسْنًا ﴾البقرة: ٨٣

មានន័យថា៖ «ចូរពួកអ្នកកុំគោរពសក្ការៈលើកលែងតែអល់ឡោះ និងកតញ្ញូចំពោះឪពុកម្ដាយ ធ្វើល្អចំពោះសាច់ញាតិ កុមារកំព្រា និងពួកអ្នកទីទ័លក្រ ហើយចូរនិយាយចុះទៅកាន់មនុស្សទាំងឡាយដោយពាក្យសម្ដីពីរោះប្រពៃ»។

## ការស្ងប់ចិត្តដោយការរំឭកព្រះ និងភាពរីករាយ៖

﴿ ٱلَّذِينَ ءَامَنُوا۟ وَتَطْمَئِنُّ قُلُوبُهُم بِذِكْرِ ٱللَّهِ ۗ أَلَا بِذِكْرِ ٱللَّهِ تَطْمَئِنُّ ٱلْقُلُوبُ ٢٨ ﴾الرعد: ٢٨

មានន័យថា៖«ពួកអ្នកដែលមានជំនឿចិត្តរបស់ពួកគេស្ងប់នឹងការសូត្រធម៌រំឭកចំពោះអល់ឡោះជាម្ចាស់។ ពិតណាស់ ការសូត្រធម៌រំឭកចំពោះអល់ឡោះធ្វើឱ្យចិត្តទទួលបាននូវសេចក្ដីស្ងប់»។

នៅចុងបញ្ចប់នៃជំពូកនេះ សូមជឿខ្ញុំចុះថា ខ្លឹមសារ លក្ខណៈពិសេស និងភាពអស្ចារ្យនៃគម្ពីរអាល់គួរអានមិនងាយនឹងផុតរលត់ គ្មានទីបំផុត។ នៅរាល់ពេលដែលយើងសូត្រអាល់គួរអាន យើងតែងរកឃើញបន្ថែមនូវអត្ថន័យខ្លឹមសារ។ យើងសូត្រវាច្រើនកាលណាធ្វើឱ្យយើងមានអារម្មណ៍ហាក់បីដូចជាបានសូត្រវាលើកដំបូង។

លើសពីនេះ ផ្នែកផ្សេងៗទៀត នៃភាសាវិទ្យា វោហារសាស្ត្រ វិទ្យាសាស្ត្រ និងអច្ឆរិយភាពនៃគម្ពីរអាល់គួរអានជាវិស័យមួយដ៏គួរឱ្យទាក់ទាញ តែក្នុងសៀវភៅនេះខ្ញុំមិនលើកយកមកសរសេរពីរឿងនេះឡើយ។ ទោះជាយ៉ាងណាក៏ដោយ ចូរព្យាយាមរកច្បាប់បកប្រែពិស្ដារពីអត្ថន័យដែលគួរឱ្យទុកចិត្ត ឬកម្មវិធីក្នុងកុំព្យូទ័រដែលបកប្រែអត្ថន័យអាល់គួរអានទាញយកពីគេហទំព័រឥស្លាមដ៏គួរឱ្យទុកចិត្ត ដូចជា (www.sultan.org)។

# ជំពូកទី៤

## ព្រះនាម និងព្រះលក្ខណៈសម្បត្តិដ៏ប្រពៃរបស់អល់ឡោះ

ខាងក្រោមនេះជាព្រះនាមមួយចំនួនរបស់អល់ឡោះ៖

- អើររ៉ោះម៉ាន (الرحمن)ព្រះដ៏មហាមេត្តា
- អើររ៉ហ៊ីម (الرحيم) ព្រះដ៏មហាករុណា
- អាល់ម៉ាលិក (الملك) ព្រះមហាក្សត្រ
- អាល់កុទ្ទូស (القدوس) ព្រះដ៏មហាពិសិដ្ឋ
- អើស្សាឡាម (السلام) ព្រះដ៏មហាសន្តិភាព
- អាល់ហាគីម (الحكيم) ព្រះដ៏មានគតិបណ្ឌិត
- អាល់អាលីម (العليم) ព្រះដ៏មហាសព្វញ្ញូ មហាដឹង
- អាល់បាសៀរ (البصير) ព្រះដ៏មហាឃើញ
- អើស្សាមៀក(السميع) ព្រះដ៏មហាលឺ
- អាល់អាទិល (العدل) ព្រះដ៏មហាយុត្តិធម៌
- អាល់អាហ្សីម (العظيم) ព្រះដ៏មហាឧត្តម

- អាល់ហ្គោហ្វ៊ូរ (الغفور) ព្រះដ៏មហាអភ័យ
- អាល់អាលីយ៍ (العلي) ព្រះដ៏មហាខ្ពង់ខ្ពស់

អ្នកនាំសារមូហាំម៉ាត់បានមានប្រសាសន៍ថា៖

عَنْ عَبْدِ اللَّهِ بْنِ مَسْعُودٍ عَنْ النَّبِيِّ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ قَالَ : (إِنَّ اللَّهَ جَمِيلٌ يُحِبُّ الْجَمَالَ ) رواه مسلم

មានន័យថា៖ «ពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់មហាសោភ័ណ ហើយទ្រង់សព្វព្រះទ័យនឹង សោភ័ណភាព»។

# ជំពូកទី៥

# សេចក្ដីបញ្ចប់

ឥស្លាមជាសាសនារបស់អាដាំ និងហាវ៉ាក ព្រមទាំងកូនចៅរបស់ពួកគាត់ទាំងពីររហូតដល់ថ្ងៃបរលោក។ ឥស្លាមពិតជាសាសនាងាយស្រួល មានហេតុផល ច្បាស់លាស់ អនុវត្តជាក់ស្ដែង។ ភាពអស្ចារ្យនៃសាសនាឥស្លាមមិនមានដែនកំណត់នោះទេ ពីព្រោះសាសនានេះមកអំពីព្រះជាម្ចាស់ដ៏មហាបុណ្យតែមួយគត់ ហើយទ្រង់ជាអ្នកបង្កើតសត្វលោក។

អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿ ٱلْيَوْمَ أَكْمَلْتُ لَكُمْ دِينَكُمْ وَأَتْمَمْتُ عَلَيْكُمْ نِعْمَتِي وَرَضِيتُ لَكُمُ ٱلْإِسْلَٰمَ دِينًا ﴾المائدة: ٣

មានន័យថា៖ «ថ្ងៃនេះយើងបានបំពេញគ្រប់លក្ខណៈសម្រាប់ពួកអ្នកនូវសាសនារបស់ពួកអ្នក យើងបានប្រទានពរជ័យ

យ៉ាងពេញលេញចំពោះពួកអ្នក ហើយយើងបានសព្វព្រះទ័យយល់ព្រមទទួលស្គាល់ឥស្លាមជាសាសនាសម្រាប់ពួកអ្នក»។

ទ្រង់បានប្រាប់យើងថា មូហាំម៉ាត់ជាអ្នកនាំសារដែលគេបញ្ជូនមកកាន់មនុស្សលោកទាំងមូល (សាសន៍មូស្លីម ជ្វីហ្វ គ្រីស្ទាន ហិណ្ឌូ ព្រះពុទ្ធ និងពួកអ្នកគ្មានជំនឿទាំងឡាយ)។

ទ្រង់បានប្រទានក្ដីចង្អុលបង្ហាញ និងពន្លឺរបស់ទ្រង់ចំពោះមនុស្សលោកទូទៅ ទ្រង់បានបើកចំហអាថ៌កំបាំងដែលនាំឆ្ពោះទៅកាន់សេចក្ដីស្ងប់ ភាពស្កប់ស្កល់ និងសន្តិភាពទាំងផ្លូវចិត្ត សង្គម និងពិភពលោកទាំងមូល។

ពិតប្រាកដ ឥស្លាមបង្រៀនយើងឱ្យប្រកាន់នូវសច្ចភាពយុត្តិធម៌ប្រកបដោយគតិបណ្ឌិត ស្មោះត្រង់ ឧស្សាហ៍ព្យាយាមក្នុងការស្វែងយល់អំពីសច្ចភាពក្នុងការទំនាក់ទំនងរបស់យើងជាមួយនឹងអ្នកដទៃ។

ប្រាកដណាស់ ការស្វែងរកការពិត គួរគប្បីឈរលើចំណេះដឹង និងប្រភពដែលគួរជាទីទុកចិត្ត។ ចំពោះការទំនាក់ទំនងរបស់

យើងជាមួយនឹងអ្នកដទៃ និងការវិនិច្ឆ័យទៅលើពួកគេ ក៏គួរគប្បីប្រព្រឹត្តិទៅដោយយុត្តិធម៌ មានដំហរវិជ្ជមាន ពិភាក្សាគ្នាដោយការគោរពគ្នាទៅវិញទៅមក និងយល់ពីគ្នាឱ្យបានច្បាស់។

## តើអ្នកគេឃើញការពិតអំពីព្យាការីចុងក្រោយហើយឬនៅ?

មូហាំម៉ាត់ ពិន អាប់ឌុលឡោះ កើតនៅមីក្កះ ក្នុងឆ្នាំ៥៧០...នៃគ.ស. ហើយសាសន៍របស់គាត់ទទួលស្គាល់ថា គាត់ជាមនុស្សប្រកាន់នូវពាក្យសច្ចៈទៀងត្រង់។ នៅពេលដែលគាត់មានអាយុ៤០ឆ្នាំ ទេវតាជីព្រីលបាននាំការត្រាស់បន្ទូលពីអល់ឡោះជាម្ចាស់មកកាន់គាត់។ សារដំបូងបង្អស់ទ្រង់បង្គាប់ប្រើឱ្យមូហាំម៉ាត់ប្រៀនប្រដៅក្រុមគ្រួសារនិងកុលសម្ព័ន្ធដែលជាប់សាច់ញាតិជិតបំផុតជាមួយគាត់ ហើយមនុស្សដំបូងបង្អស់គឺប្រពន្ធរបស់គាត់ខទីហ្ជះ។ បន្ទាប់មកការត្រាស់បន្ទូលឱ្យបញ្ជូនសារនេះ ទៅកាន់មនុស្សលោកទូទៅ។ ក្នុងមួយជីវិតរបស់គាត់ គាត់បានពាំនាំសារនេះទៅកាន់សាសន៍ដទៃ ហើយគាត់ជាគំរូល្អសម្រាប់មនុស្សទូទៅ។

នៅឆ្នាំ៦៣៣គ.ស.ព្យាការីមូហាំម៉ាត់បានលាចាកលោកក្នុងជន្មាយុ៦៣ឆ្នាំ។

ពិតណាស់ ព្យាការីមូហាំម៉ាត់ជាព្យាការី និងជាអ្នកនាំសារចុងក្រោយ។ ជាព្យាការីចុងក្រោយដែលគេបញ្ជូនមកដើម្បីបញ្ជាក់ពីការពិតដែលគេបានត្រាស់បង្គាប់ទៅកាន់ពួកព្យាការីសម័យមុនរួមមានគម្ពីរសញ្ញាថ្មីរបស់យេស៊ូដោយសំអាងលើសម្តីរបស់គាត់ថា៖

មានន័យថា៖ «នរណាមានជំនឿចំពោះអ៊ីសា ហើយមានជំនឿចំពោះខ្ញុំ ដូច្នេះគេទទួលបានផលបុណ្យទ្វេដង»។

ព្យាការីគាត់បានមានប្រសាសន៍ទៀតថា៖

មានន័យថា៖ «ខ្ញុំគឺជាមនុស្សដែលជិតជិតជាមួយនឹងអ៊ីសាកូននាងម៉ារីជាងគេ...»។

ប្រសាសន៍របស់ព្យាការីបង្ហាញឱ្យឃើញថា គាត់បានសរសើរចំពោះអ៊ីសា។ គម្ពីរសញ្ញាណថ្មីក៏មាននិយាយពីព្យាការីមូហាំម៉ាត់ ហើយខ្ញុំនឹងបង្ហាញក្នុងពេលបន្តិចទៀត។

# បុគ្គលិកលក្ខណៈដ៏ឧត្តមរបស់មូហាំម៉ាត់

ពួកមហាបុរសក្នុងប្រវត្តិសាស្ត្រដែលប្រកាន់នូវសច្ចធម៌មិនលម្អៀងបានយល់ឃើញថា មូហាំម៉ាត់តាំងពីវ័យកុមាររហូតដល់យុវវ័យ និងពីពេលក្លាយជាព្យាការីរហូតដល់ស្លាប់ បុគ្គលិកលក្ខណៈរបស់គាត់ឧត្តមឯក ទាំងសីលធម៌ ក្តីមេត្តាករុណា សច្ចៈទៀងត្រង់ ស្មោះត្រង់ មានភក្តីភាព ឱនលំទោន ចិត្តសប្បុរស និងលក្ខណៈសម្បត្តិប្រពៃផ្សេងៗទៀត។ តាមពិត រាល់កាបកស្រាយពិស្តារពីជីវិតសកម្មភាពផ្ទាល់ខ្លួន និងសកម្មភាពទូទៅរបស់គាត់ ច្បាស់ណាស់ថាគាត់ជាព្យាការី ជាអ្នកនាំសារ ជាបរមគ្រូ ជាអ្នកផ្សះផ្សា ជាមគ្គទេសក៍ទៅកាន់សីលធម៌ឧត្តុង្គឧត្តម គំរូដ៏ល្អ ជាមេទ័ព ជាអ្នកនយោបាយ ជាមិត្តដ៏មានមេត្រីភាព ជាប្តីដ៏ជាទីស្រលាញ់ ជាឪពុកដ៏មានព្រហ្មវិហារធម៌។

លើសពីនេះ ក្នុងសៀវភៅដែលមានចំណងជើងថា «មូហាំម៉ាត់ជាព្យាការីឥស្លាម» សាស្ត្រាចារ្យទស្សនវិទូឥណ្ឌា លោក រាម ក្រស្នា យល់ឃើញថា មូហាំម៉ាត់ជាគំរូដ៏សុក្រឹតពេញលក្ខណៈសម្រាប់ជីវិតរស់នៅរបស់មនុស្ស។ លោកបកស្រាយបញ្ជាក់ពីការពណ៌នានេះថា ជារឿងមួយពិបាកក្នុងការសិក្សាស្វែងយល់ឱ្យបានស៊ីជម្រៅនៃ

បុគ្គលិកលក្ខណៈរបស់មូហាំម៉ាត់ វាគ្រាន់តែជាការឆ្លុះបញ្ចាំងដោយសង្ខេបពីបុគ្គលិកលក្ខណៈរបស់មូហាំម៉ាត់ បើសិនជាអាចខ្ញុំនឹងសរសេរពិស្តារជាភាគៗស្តីអំពីតថភាពនៃជីវប្រវត្តិដ៏មហាអស្ចារ្យនេះ។

មូហាំម៉ាត់ជាព្យាការី ជាវីរជនធ្វើសង្គ្រាម ជាឈ្មួញ ជាអ្នកនយោបាយ ជាកវីដ៏មានវោហារសាស្រ្ត ជាអ្នកផ្សះផ្សា ជាទីពឹងសម្រាប់កុមារកំព្រា ជាមេធាវី ជាអ្នករំដោះទាសករ ជាអ្នកសង្គ្រោះស្រ្តីឱ្យមានសិទ្ធិសេរីភាព ជាតុលាការកាត់ក្តី ជាចៅហ្វាយដ៏ស្មោះត្រង់ក្រៅពីតួនាទីក្នុងវិស័យមនុស្សជាតិដ៏ឧត្តុង្គឧត្តមនេះ លោកជាវីរជនក្លាហានម្នាក់ផងដែរ។

ប្រវត្តិវិទូម្នាក់បានសរសេរថា ពិតណាស់ មូហាំម៉ាត់បានចាប់ផ្តើមបំពេញបេសកម្មអំពាវនាវឱ្យមនុស្សមកកាន់សាសនាដ៏សច្ចៈនេះ (ឥស្លាម)នៅអាយុ៤០ឆ្នាំ ហើយបានលាចាកលោកយើងនេះនៅអាយុ៦៣ឆ្នាំ។ ក្នុងរយៈពេលដ៏ខ្លីនេះ (ប្រហែលជា២៣ឆ្នាំ) សាររបស់គាត់ពុំទាន់គ្របដណ្តប់លើឧបទ្វីបអារ៉ាប់ទាំងមូលនៅឡើយទេ។ រំដោះមនុស្សជាតិឱ្យរួចផុត

- ពីការគោរពពហុទេព រូបសំណាកទៅកាន់ការគោរពសក្ការៈចំពោះអល់ឡោះតែមួយ។
- ពីទំនាស់ និងសង្គ្រាមទៅរកការរួបរួម និងសាមគ្គីភាព។
- ពីការផឹកស្រា អសីលធម៌ទៅរកឧត្តមភាព និងជំនឿស៊ប់លើសាសនា។
- ពីអនាធិបតេយ្យ គ្មានច្បាប់ទម្លាប់ ទៅរកការរស់នៅដែលមានសណ្តាប់ធ្នាប់ និងមានប្រព័ន្ធច្បាប់គ្រប់គ្រង។
- ពីការស្រុតចុះដុនដាបនៃសីលធម៌សង្គមទៅរកកម្រិតខ្ពស់បំផុតនៃសីលធម៌។

ពិតណាស់ ក្នុងប្រវត្តិសាស្រ្តមនុស្សជាតិពុំដែលឃើញមានការប្រែប្រួលផ្លាស់ប្តូរក្នុងសង្គម។ ទោះមុនឬក្រោយណាមួយដូចជាការផ្លាស់ប្តូរនៅសម័យគាត់។ ការផ្លាស់ប្តូរដ៏អស្ចារ្យនេះ ប្រព្រឹត្តិទៅក្នុងរយៈពេលតែពីរទសវត្សប៉ុណ្ណោះ។

## មូហាំម៉ាត់ក្នុងគម្ពីរបីប៊ះ

ពិតប្រាកដ សៀវភៅនេះគ្មានបំណងលើកយកទំនាយពីការមកដល់របស់ព្យាការីមូហាំម៉ាត់ក្នុងគម្ពីរសាសនាផ្សេងៗមកសរសេរនោះទេ ប៉ុន្តែពួកសាសនវិទូឥស្លាមបានបកស្រាយខ្លះពីទំនាយដែលមាននៅក្នុងគម្ពីររបស់ពែក ហិណ្ឌូ ព្រះពុទ្ធ សាសនាជ្វីហ្វ និងគ្រិស្តសាសនា។

តាមពិត ប្រធានបទនេះ (មូហាំម៉ាត់ក្នុងគម្ពីរពិសិដ្ឋផ្សេងៗ) ត្រូវបានលើកមកពិគ្រោះពិភាក្សាយ៉ាងច្រើន ថែមទាំងបានយកមកចងក្រងជាសៀវភៅ អត្ថបទបង្ហោះតាមប្រព័ន្ធអ៊ិនធឺណែត។ ដើម្បីទទួលពត៌មានបន្ថែមអំពីប្រធានបទនេះសូមទៅកាន់គេហទំព័រ www.inf.net។

លោក អាប់ឌុលអាហាត ដាវូត (អតីតបព្វជិតសាសនាគ្រិស្ត ដេវីត ពិនយ៉ាមិន) ក្នុងសៀវភៅដ៏ល្បីល្បាញរបស់គាត់ដែលមានចំណងជើងថា (មូហាំម៉ាត់ក្នុងគម្ពីរពិសិដ្ឋផ្សេងៗ) លោកសរសេរអត្ថបទគម្ពីរពិសិដ្ឋនិយាយពីការមកដល់នៃព្យាការីម្នាក់ដែលដូចមូសា ដោយលោកបាននិយាយថា៖ «យើងនាំគ្នាអានក្នុងទំនុក

តម្កើង ជំពូក...មាត្រា... (យើងនឹងបង្កើតសម្រាប់ពួកគេនូវព្យាការី ម្នាក់ពីក្នុងចំណោមបងប្អូនរបស់ពួកគេដូចអ្នក ហើយយើងនឹងដាក់ បន្ទូលរបស់យើងក្នុងមាត់របស់គេ) បើសិនជាពាក្យនេះមិនត្រូវចំពោះ មូហាំម៉ាត់ ដូច្នេះទំនាយនេះមិនទាន់ប្រាកដទេ ព្រោះយេស៊ូខ្លួនឯង មិនបានអះអាងថា គាត់ជាព្យាការីដែលមានចែងក្នុងបន្ទូលនេះដែរ»។

បើយោងតាមជំនឿនៃគោរមងារ យេស៊ូគាត់កើតមកគ្រាន់ តែមានតួនាទីជាអ្នកកាត់ក្តី ឬវិនិច្ឆ័យ ពុំមែនជាអ្នកបញ្ញត្តិច្បាប់នោះ ទេ។ រីឯព្យាការីក្នុងទំនាយដែលបានសន្យានោះនឹងនាំមកនូវ "ច្បាប់ដ៏ ត្រចះត្រចង់" ដោយ "ដៃស្តាំរបស់គេ"។

ពួកអ្នកប្រាជ្ញឥស្លាមបញ្ជាក់ថាទំនាយនេះគ្មានត្រូវលើ នរណាផ្សេងក្រៅពីមូហាំម៉ាត់។ ប្រាកដណាស់ មូហាំម៉ាត់ និងមូសា មានលក្ខណៈស្រដៀងគ្នាច្រើនប្រការដូចជា៖

- ឈ្មោះរបស់គាត់ទាំងពីរផ្តើមដោយអក្សរតែមួយគឺ (ម)។
- កំណើត មានគ្រួសារ ភារកិច្ច និងការស្លាប់របស់គាត់ទាំង ពីរមានលក្ខណៈប្រក្រតីដូចគ្នា។

- គាត់ទាំងពីរជាព្យាការីផង ជាអ្នកនាំសារផង ជាអ្នកគ្រប់គ្រង ជាមេទ័ព ជាអ្នកនយោបាយ ហើយក៏ជាអ្នកបញ្ញត្តិច្បាប់ផងដែរ។

ផ្ទុយទៅវិញ យេស៊ូមិនដូចមូសាក្នុងប្រការជាច្រើន។ អ្នកដើរតាមយេស៊ូចាត់ទុកគាត់ជាព្រះ ឬបុត្ររបស់ព្រះ ហើយកំណើត ភារកិច្ច និងទីបញ្ចប់របស់គាត់មិនដូចមូសានោះទេ។ យេស៊ូពុំបានយកប្រពន្ធ មិនមែនជាអ្នកគ្រប់គ្រងសាសន៍របស់គាត់ ហើយពុំបានធ្វើសង្គ្រាមក្នុងសមរភូមិ ដូចជាមូសានោះទេ។ នេះបើយោងតាមអ្វីដែលមានចែងក្នុងគម្ពីរពិសិដ្ឋ (គម្ពីរសញ្ញាណថ្មី)។

ជាងនេះទៅទៀត គម្ពីរពិសិដ្ឋបានចែងថា៖ «ព្យាការីម្នាក់មកពីក្នុងចំណោមបងប្អូនរបស់ពួកគេ»។ ចង់បង្ហាញប្រាប់ពីព្យាការីម្នាក់កើតចេញពីបងប្អូនរបស់សាសន៍អ៊ីស្រាអែល គឺកូនចៅរបស់ព្យាការីអ៊ីស្មាអែល។ បន្ថែមពីលើទំនាយនេះ យេស៊ូក្នុងគម្ពីរសញ្ញាណថ្មីនៃគម្ពីរប៊ីបបានប្រាប់ដំណឹងល្អពីការមកដល់របស់ «អ្នកសង្គ្រោះម្នាក់ទៀត» ហើយយេស៊ូបាននិយាយយ៉ាងច្បាស់លថា៖ « ទ្រង់នឹងប្រទានឱ្យពួកអ្នកនូវអ្នកសង្គ្រោះម្នាក់ទៀត» សៀវភៅយូហាន ។

ចូរត្រលប់ទៅអានសៀវភៅយូហាន ....។

ដូច្នេះ តើនរណាជាអ្នកសង្គ្រោះ(ព្យាការី)ចុងក្រោយដែលនឹងមកបន្ទាប់ពីយេស៊ូ?

ពួកអ្នកប្រាជ្ញមូស្លីមបានបញ្ជាក់ថា មូហាំម៉ាត់ជាអ្នកបំពេញនូវដំណឹងល្អដែលយេស៊ូបានប្រាប់ ដោយផ្អែកលើហេតុផលជាច្រើនដូចខាងក្រោម៖

- អ៊ីសាបាននិយាយថា៖ «ទ្រង់នឹងឱ្យពួកអ្នកនូវអ្នកសង្គ្រោះម្នាក់ទៀត» (យូហាន...)។ ពួកអ្នកប្រាជ្ញមូស្លីមខ្លះបាននិយាយថា នាមសព្ទដើមនៃពាក្យអ្នកសង្គ្រោះនេះមកពីពាក្យក្រិក (Paraclete) ដែលមានន័យថា (អ្នកដែលត្រូវគេសរសើរ ឬលើកតម្កើង) គឺសំដៅដល់ឈ្មោះមូហាំម៉ាត់នេះតែម្ដង។
- ការបង្ហាញប្រាប់របស់យេស៊ូពី "អ្នកសង្គ្រោះម្នាក់ទៀត" មិនត្រូវនឹងវិញ្ញាណបរិសុទ្ធនោះទេ ពីព្រោះវិញ្ញាណបរិសុទ្ធ

ជាចំណែកនៃជំនឿត្រីម៉ុតិ ព្រះបិតា ព្រះបុត្រា និងវិញ្ញាណបរិសុទ្ធ។ យោងតាមជំនឿគ្រិស្តសាសនាដែលជឿលើលទ្ធិត្រីម៉ុតិ វិញ្ញាណបរិសុទ្ធគឺមានមុន និងក្នុងកំឡុងពេលនៃសាររបស់យេស៊ូដោយយោងតាមគម្ពីរប៊ីប។ ក៏ប៉ុន្តែអ្នកសង្គ្រោះនេះនឹងមកបន្ទាប់ពីយេស៊ូ។

- លើសពីនេះ ព្យាការីមូហាំម៉ាត់មកដើម្បីទូន្មានប្រៀនប្រដៅមនុស្សលោកទាក់ទងនឹងអល់ឡោះជាព្រះពិតតែមួយអង្គគត់ ចង្អុលបង្ហាញផ្លូវពួកគេទៅកាន់ជីវិតពិត និងគោលបំណងនៃជិវិត ហើយប្រាប់ពួកគេឱ្យដឹងពីសារជាតុពិតនៃសេចក្តីស្លាប់ ថ្ងៃបរលោក និងជីវិតអតមៈ ក៏ដូចជាអំពីចំណេះដឹង និងប្រការពិតផ្សេងៗជាច្រើនទៀត។
- ជាមួយគ្នានេះគាត់ក៏បានប្រាប់ពួកយើងពីដំណឹងផ្សេងៗទំនាយ និងអច្ឆរិយភាពជាច្រើនដែលអល់ឡោះជាម្ចាស់បានប្រទាន និងបង្រៀនដល់គាត់។
- មូហាំម៉ាត់ជាព្យាការីដែលមិននិយាយចេញពីមនោវិតក្កនោះទេ តែបានស្តាប់ និងទទួលការត្រាស់បន្ទូលពីអល់ឡោះជាម្ចាស់ ដែលទ្រង់បាននិយាយប្រាប់ពីដំណឹងមូហាំ

ម៉ាត់នេះនៅក្នុងគម្ពីរសញ្ញាណថ្មី។ យេស៊ូបានប្រាប់ពីទំនាយនេះក្នុងសៀវភៅយ៉ូហាន ជំពូក....។ អល់ឡោះជាម្ចាស់ទ្រង់បានត្រាស់បន្ទូលរបស់ទ្រង់ជាគម្ពីរអាល់គួរអានដល់មូហាំម៉ាត់។ ព្យាការីមូហាំម៉ាត់បានសូត្រគម្ពីរអាល់គួរអាននេះក្នុងព្រះនាមអល់ឡោះ (ក្នុងព្រះនាមអល់ឡោះមហាមេត្តា មហាករុណា)។ ទំនាយផ្សេងទៀតអំពីមូហាំម៉ាត់ក្នុងគម្ពីរសញ្ញាណថ្មីដែលចែងថា៖ «គេនឹងនិយាយក្នុងព្រះនាមរបស់អល់ឡោះ» (សៀវភៅទំនុកតម្កើង ជំពូក...មាត្រា....)។ ដាក់ស្ដែងជំពូក១ក្នុងគម្ពីរអាល់គួរអានចាប់ផ្ដើមដោយពាក្យ «ក្នុងព្រះនាមរបស់អល់ឡោះមហាមេត្តា និងមហាករុណា»។

ពិតណាស់ ព្យាការីមូហាំម៉ាត់ និងគម្ពីរអាល់គួរអានបានលើកតម្កើងដល់យេស៊ូយ៉ាងខ្លាំងក្លាជាទីបំផុត ក៏ដូចជា ពួកអ្នកមូស្លីមទូទៅបានផ្ដល់កិត្តិយស ស្រលាញ់ និងគោរពចំពោះយេស៊ូ រហូតដល់ពួកគេដាក់ឈ្មោះកូនៗរបស់ពួកគេថា អ៊ីសា (យេស៊ូ)។

លើសពីនេះ នៅពេលដែលពួកជ្វីហ្វសួរយ៉ូហាន (យ៉ះយ៉ា)ថា តើលោកជានរណា? គាត់បានទទួលស្គាល់ថា ខ្ញុំពុំមែនជាមេ

ស៊ីទេ។ ពួកគេសួរបន្តទៀតថា ចុះលោកជាអ្វីទៅវិញ? តើលោកជាអ៊ីលីយ៉ាឬ(អិលយើស)? លោកតបវិញថា ក៏ពុំមែនដែរ។ តើលោកជាព្យាការីនោះមែនទេ? លោកឆ្លើយថា ទេ! សៀវភៅយូហាន ជំពូកលេខ....។

ដូចដែលយ៉ះយ៉ាបានទទួលស្គាល់ខាងលើថា លោកពុំមែនជាអ៊ីលីយ៉ះ ពុំមែនជាយេស៊ូនោះទេ។

ដូច្នេះ អ្នកសិក្សាស្រាវជ្រាវរកការពិតដោយគតិបណ្ឌិត សច្ចៈទៀងត្រង់ និងមានសទ្ធាជ្រះថ្លានោះ គួរគប្បីសិក្សាស្វែងយល់ដោយផ្អែកលើហេតុផលច្បាស់លាស់ថា៖

## តើនរណាជាព្យាការី?

តើនរណាជាព្យាការីពិតដែលមកបន្ទាប់ពីអ៊ីលីយ៉ា និងយេស៊ូដើម្បីផ្សព្វផ្សាយសារច្បាប់ដើម និងបរិសុទ្ធស្តីអំពីអល់ឡោះជាព្រះជាម្ចាស់តែមួយអង្គគត់ ទ្រង់គ្មានដៃគូ? ប្រាកដណាស់ គាត់គឺព្យាការីមូហាំម៉ាត់។

## ដំណាក់ស្រង់សម្តីដែលគេនិយាយអំពីព្យាការីមូហាំម៉ាត់៖

គេបាននិយាយ និងសរសេរជាច្រើនអំពីព្យាការីមូហាំម៉ាត់តាមរយៈទំព័រប្រវត្តិសាស្ត្រ។ តទៅនេះសូមលើកយកមកបង្ហាញខ្លះនូវសម្តីរបស់អ្នកប្រាជ្ញល្បីៗដូចជា

ប្រវត្តិវិទូល្បីរបស់បារាំងលោកឡាម៉ាទីនបាននិយាយថា៖

«បើសិនជានិយាយពីទិសដៅធំ មធ្យោបាយតូចលទ្ធផលដ៏គួរឱ្យភ្ញាក់ផ្អើល គឺជាលក្ខណៈស្តង់ដារបីនៃទេពកោសល្យរបស់មនុស្ស។ តើនរណាហ៊ានយកវីរបុរសដ៏ល្បីល្បាញណាម្នាក់ក្នុងប្រវត្តិសាស្ត្រសម័យទំនើបទៅប្រៀបនឹងមូហាំម៉ាត់ទេ ?»។

លោក ឡាម៉ាទីនបាននិយាយដោយម៉ឺងម៉ាត់ថា «ស្របនឹងគ្រប់លក្ខណៈស្តង់ដារទាំងអស់ដែលគេអាចប្រៀបធៀបពីឧត្តមភាពរបស់មនុស្ស យើងចាំបាច់ត្រូវតែសួរថា តើមានបុគ្គលណាប្រសើរជាងរូបគាត់ទេ ?»។

លោក ម៉ៃខឹល ហាត ក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា «ឋានានុក្រមនៃវីរជនពិភពលោកទាំងមួយរយនាក់

ដែលមានឥទ្ធិពលជាងគេក្នុងប្រវត្តិសាស្រ្ត»បានសរសេរថា «ប្រាកដណាស់ ខ្ញុំជ្រើសរើសយកមូហាំម៉ាត់ដាក់លេខរៀងទី១ក្នុងបញ្ជីវីរជនពិភពលោកដែលមានឥទ្ធិពលជាងគេចំពោះមនុស្សជាតិ។ អាចមានអ្នកអានខ្លះភ្ញាក់ផ្អើល ហើយជួនកាលអាចបដិសេធ ក៏ប៉ុន្តែលោកពិតជាវីរជនតែមួយគត់ក្នុងប្រវត្តិសាស្រ្ត ដែលសម្រេចបាននូវភាពជោគជ័យយ៉ាងលេចធ្លោបំផុត ទាំងផ្នែកសាសនា និងអាណាចក្រ»។

លោក ប៉ែរណាត សូ ក្នុងសៀវភៅរបស់លោក (ភាពពិតឥតល្អៀងនៃសាសនាឥស្លាម) បានសរសេរថា «តាមយោបល់របស់ខ្ញុំ បើសិនជាលោកដឹកនាំពិភពលោកសព្វថ្ងៃ លោកនឹងអាចដោះស្រាយគ្រប់បញ្ហារបស់យើងដោយជានាបាននូវសន្តិភាព សុភមង្គល ដែលមនុស្សលោកកំពុងទន្ទឹងរង់ចាំ»។

សម្តីរបស់លោក មហាត្មាត់ គ្ពាន់ធី « ខ្ញុំយល់ស្របទាំងស្រុងថា ផ្លែដាវពុំមែនជាមធ្យោបាយដែលឥស្លាមប្រើដើម្បីពង្រីកនិងពង្រឹងអំណាចរបស់ខ្លួននោះទេ។ តែផ្ទុយទៅវិញជាធម្យោបាយងាយៗបំផុតដោយភាពហ្មត់ចត់ ការគោរពពាក្យសន្យា ការលះបង់ និងចិត្តជ្រះថ្លារបស់លោកចំពោះសហការី និងមិត្តភក្តិរបស់លោក រួមទាំង

ភាពក្លាហានជាមួយនឹងជំនឿទុកចិត្តយ៉ាងដាច់ខាតរបស់លោកចំពោះព្រះជាម្ចាស់ និងសាររបស់លោក»។

សម្តីរបស់ វ៉ុល្វគ្គុង កោស៊ី «លោកគឺជាព្យាការី ពុំមែនជាកវី ដូច្នេះ ចាំបាច់ត្រូវចាត់ទុកថាអាល់គួរអានរបស់លោកជាគម្ពីរមកពីលើមេឃ តែពុំមែនជាសៀវភៅដែលនិពន្ធដោយមនុស្សលោកដែលបាននិពន្ធឡើងដើម្បីសិក្សា និងកម្សាន្តនោះឡើយ»។

ក្នុងសៀវភៅច្បាប់ថ្មីរបស់លោកដែលមានឈ្មោះថា ឥស្លាមជាផ្លូវដ៏ត្រឹមត្រូវ លោក ចន អេស្តើសជីអូ (សាស្ត្រាចារជនជាតិអាមេរិកផ្នែកសាសនា និងទំនាក់ទំនងអន្តរជាតិ) បានសរសេរថា «មូហាំម៉ាត់ឋិតក្នុងចំណោមមហាបុរសសាសនាដ៏ឧត្តុង្គឧត្តម ជាព្យាការី ជាស្ថាបនិកសាសនា ហើយលោកមានសីលធម៌ និងបុគ្គលិកលក្ខណៈពិសេសអស្ចារ្យដែលជំរុញឱ្យមានភាពជឿជាក់ និងខ្ជាប់ខ្ជួនមិនធ្លាប់មានពីមុនមក។ ប្រាកដណាស់ ទិដ្ឋភាពនៃជ័យជំនះរបស់លោកក្នុងការទាក់ទាញអ្នកដើរតាម ហើយបានបង្កើតរដ្ឋនៃប្រជាជាតិមួយដែលអាចគ្រប់គ្រងលើទឹកដីអារ៉ាប់ទាំងមូល។ លោកមិនគ្រាន់តែអាចសង្គ្រោះបានដោយលោកជាអ្នករៀបចំយុទ្ធសាស្ត្រទ័ពដ៏ពូកែប៉ុណ្ណោះ

ទេ តែលោកគឺជាបុរសដែលមិនធម្មតា....ហើយជាមនុស្សដែលមានក្តីមេត្តា» (ចន អេស្តើសជីអូ ឆ្នាំ......)។

លោក អេស្តើសជីអូ បានបញ្ជាក់ទៀតថា «មូហាំម៉ាត់ពុំមែនជាស្ថាបនិកឥស្លាម ហើយលោកក៏ពុំបានស្ថាបនាពិភពលោកថ្មីផងដែរ»។

លោកសាស្ត្រាចារ្យ អេស្តើសជីអូ បានបញ្ជាក់ពីខ្លឹមសារនេះក្នុងសៀវភៅឈ្មោះ (ការនាំឥស្លាមទៅកាន់កំណែទម្រង់) គឺការអំពាវនាវជាថ្មីម្តងទៀតឱ្យគោរពប្រណិប័តន៍ពេញលេញចំពោះអល់ឡោះ អនុវត្តតាមក្តីបង្គាប់របស់ទ្រង់ ដូចដែលទ្រង់បានត្រាស់បង្គាប់មកចំពោះមូហាំម៉ាត់ឱ្យបានត្រឹមត្រូវមួយរយភាគរយតាមមាត្រាគម្ពីរ ហើយលោកគឺជាព្យាការីចុងក្រោយបង្អស់។ ដូច្នេះ ចំពោះមូហាំម៉ាត់ឥស្លាមពុំមែនជាជំនឿថ្មី ក៏ប៉ុន្តែគ្រាន់តែនាំត្រឡប់មកវិញនូវ ជំនឿដ៏ត្រឹមត្រូវ សុក្រឹតឥតខ្ចោះតែប៉ុណ្ណោះ។

ពាក្យប្រសាសន៍ដ៏ប្រពៃរបស់ព្យាការីមូហាំម៉ាត់៖

- (ពាក្យពីរោះជាការដាក់ទានមួយ) រាយការណ៍ដោយអាល់ពូខរីយ៍។
- (ស្នាមញញឹមរបស់អ្នកទៅកាន់បងប្អូនរបស់អ្នកក៏ជាការដាក់ទានមួយដែរ) រាយការណ៍ដោយ អាត់តួរមីហ្ស៊ីយ៍។
- (ពិតណាស់ អ្នកដែលប្រសើរជាងគេក្នុងចំណោមពួកអ្នកគឺអ្នកដែលមានសីលធម៌ល្អជាងគេ) រាយការណ៍ដោយអាល់ពូខរីយ៍។
- (ការសម្អាតផ្លូវពីបន្លាក្រួសក៏ជាការដាក់ទានដែរ) មុតតាហ្វាកុន អាឡៃហ៊ី។
- (ជំនឿដ៏ប្រសើរបំផុតគឺការអត់ធ្មត់ និងការអត់ឱន) រាយការណ៍ដោយ អាល់ហៃហាកីយ៍ ចាត់គន្ថៈនិទ្ទេសសហេស ដោយអាល់ហ្គានីយ៍។
- (ពិតណាស់ បុរសម្នាក់បានសួរព្យាការីមូហាំម៉ាត់ថា តើក្នុងឥស្លាមប្រការណាដែលជាអំពើល្អ? លោកឆ្លើយថា ផ្ដល់ចំណីអាហារ ស្វាគមន៍ដោយសាឡាមចំពោះអ្នកស្គាល់ និងអ្នកមិនស្គាល់) រាយការណ៍ដោយ អាល់ពូខរីយ៍។

លើសពីនេះ លោកបានមានប្រសាសន៍ទៀតថា៖

- (ពួកអ្នកដែលមានចិត្តមេត្តា ព្រះនឹងមេត្តាចំពោះពួកគេ ចូរមេត្តាចំពោះមនុស្សទូទៅនៅលើផែនដី អ្នកនៅលើមេឃនឹងមេត្តាចំពោះពួកអ្នក)រាយការណ៍ដោយត្ទរមីហ្ស៊ីយ៍។
- (នរណាក៏ដោយក្នុងចំណោមពួកអ្នក ពុំទាន់មានជំនឿពេញលក្ខណៈទេ លុះត្រាតែគេស្រឡាញ់បងប្អូនរួមជំនឿរបស់ខ្លួនដូចគេស្រលាញ់ខ្លួនឯងដែរ)។
- (ពុំមែនជាអ្នកមានជំនឿទេ ដែលខ្លួនហូបឆ្អែត ហើយញាតិជិតខាងរបស់ខ្លួននៅស្រេកឃ្លាននោះ) រាយការណ៍ដោយអាល់ហៃ្ហហាគីយ៍ ចាត់គន្ថៈនិទ្ទេសសហេសដោយអាល់ហ្គានីយ៍។
- (ពុំមែនហៅអ្នកខ្លាំងទេ អ្នកដែលពូកែបោកចំបាប់ តែដែលហៅថាអ្នកខ្លាំងនោះគឺអ្នកដែលចេះទប់ចិត្តនៅពេលខឹង) សៀវភៅអាល់មូវ័ត្តក់ អ៊ីម៉ាំ ម៉ាលិក។
- (ពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់មិនទតមើលខ្លួនប្រាណ និងរូបរាងរបស់ពួកអ្នកនោះទេ តែទ្រង់ទតមើលចិត្តរបស់ពួកអ្នក) រាយការណ៍ដោយមូស្លីម។

- (អ្នកដែលប្រសើរជាងគេក្នុងចំណោមពួកអ្នក គឺអ្នកដែលធ្វើល្អជាងគេចំពោះគ្រួសាររបស់ខ្លួន ហើយខ្ញុំជាអ្នកដែលធ្វើល្អចំពោះគ្រួសាររបស់ខ្ញុំជាងពួកអ្នក)។
- (អ្នកដែលប្រសើរជាងគេក្នុងចំណោមពួកអ្នក គឺអ្នកដែលធ្វើល្អជាងគេចំពោះប្រពន្ធរបស់ខ្លួន) រាយការណ៍ដោយ អាត់តួរមីហ្ស៊ីយ៍ និង អ៊ិបនូ ម៉ាហ្ជះ។
- (មនុស្សដែលប្រសើរជាងគេ គឺអ្នកដែលមានប្រយោជន៍ជាងគេសម្រាប់មនុស្ស) រាយការណ៍ដោយ ដារ៉ូកុតនីយ៍ ចាត់គន្លះនិទ្ទេសសហេសដោយ អាល់ហ្គានីយ៍។

ទាំងនេះ គ្រាន់តែជាគំរូនៃប្រសាសន៍ដ៏ប្រពៃប្រកបដោយគតិបណ្ឌិតរបស់ព្យាការីមូហាំម៉ាត់តែប៉ុណ្ណោះ ។

# មាតិកា

## ជំពូកទី១


មូលដ្ឋានគ្រឹះនៃឥស្លាម........................................១

...ឥស្លាម?..........................................................៥


## ជំពូកទី២


ឆ្លើយតបនឹងសំណួរស្លាប់រស់................................១១

តើអ្វីជាការពិត?...............................................១២

តើនរណាជាព្រះពិត?.........................................២២

តើអ្នករកអាថ៌កំបាំងឃើញហើយឬនៅ?.................២៥

គោលជំនឿទាំងប្រាំមួយ......................................៣១

គោលគ្រឹះឥស្លាមទាំងប្រាំ...................................៣៤


## ជំពូកទី៣


សោភ័ណភាពនិងភាពបរិសុទ្ធនៃគម្ពីរអាល់គួរអាន.....៤៤

ការសង្គ្រោះនិងការអភ័យទោស............................៤៦

យុត្តិធម៌..........................................................៤៨

សមភាពក្នុងឥស្លាម..........................................៥៤

សកលនីយកម្មនិងភាពតែមួយនៃសារឥស្លាម...........៥៨

សេចក្តីស្ងប់និងឋានសួគ៌.......................................៦១
បុរសនិងស្ត្រី.........................................................៦២
ជាគោលការណ៍ដ៏ឧត្តុង្គឧត្តម...............................៦៣
បទបញ្ញានិងបម្រាម...............................................៦៥
ការសូត្រធម៌រំឭកព្រះ និងភាពរីករាយ.....................៦៥
ជំពីទី៤
ព្រះនាមនិងព្រះលក្ខណៈសម្បត្តិរបស់អល់ឡោះ.......៦៧
ជំពូកទី៥
សេចក្តីបញ្ចប់.........................................................៦៩

អង្គការវប្បធម៌  អារ្យធម៌កម្ពុជា_អារ៉ាប់
Cambodia Arab Cultural Civilizational Organization